# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center**

*ក្នុងពេលដែលវើចូលទៅដល់ហើយ (ភ្នំពេញ) ឃើញនៅតាមផ្ទះថ្ម មាន សុទ្ធតែទង់ជ័យសទាំងអស់ គឺទីក្រុងស្ងាត់ គ្មានមនុស្សម្នាអីទេ ស្ងាត់ទាំងអស់បាទ។*

*- សាក្សី មាស វឿន*

## *ជំពូកទី ១ ៖* **និដ្ឋភាពទូទៅ**

នាសប្តាហ៍នេះ អង្គជំនុំជម្រះបានចាប់ផ្តើមស្តាប់សក្ខីកម្មរបស់លោក **ខៀវ អេន** ជាបុគ្គលម្នាក់ដែលធ្លាប់មានភារកិច្ចទទួលខុសត្រូវនៅក្នុងក្រសួងឃោសនាការ និងអប់រំ នៃរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់មក អង្គជំនុំជម្រះ បានចំណាយពេលក្នុងការអានសម្រង់ពីដីកាដំណោះស្រាយទាក់ទងនឹងរចនាសម្ព័ន្ធយោធា និងការផ្លាស់ទីប្រជាជន ដែលប្រធានបទនេះស្ថិតនៅក្នុងវគ្គទី៣នៃសំណុំរឿង០០២/១ ។ បន្ទាប់មក អង្គជំនុំជម្រះបានកោះហៅអតីតមន្ត្រីយោធាម្នាក់ក្នុងរបបខ្មែរក្រហម គឺលោក **មាស វឿន** មកកាន់សវនាការដើម្បីផ្តល់សក្ខីកម្ម ។

ជនជាប់ចោទ **អៀង សារី** បានបន្តអវត្តមានក្នុងកិច្ចដំណើរការសវនាការពេញមួយសប្តាហ៍ ដោយគាត់បានលះបង់សិទ្ធិមានវត្តមានក្នុងការស្តាប់សក្ខីកម្មរបស់លោក **ខៀវ អេន** និងលោក **មាស វឿន**។[1]កាលពីរសៀលថ្ងៃអង្គារ អង្គជំនុំជម្រះ បានសម្រេចអញ្ជើញភាគីទាំងអស់ឲ្យដាក់សំណើផ្ទាល់មាត់អំពីរបៀបដែលត្រូវបន្តដំណើរការកាត់សេចក្តីរបស់ **អ.វ.ត.ក** ដើម្បីឲ្យឆ្លើយតបទៅនឹងស្ថានភាពសុខភាពដ៏យ៉ាប់យ៉ឺនរបស់ជនជាប់ចោទ **អៀង សារី**។ បញ្ហាផ្សេងៗទៀតទាក់ទងនឹងការគ្រប់គ្រងតុលាការ ក៏ត្រូវបានលើកឡើងផងដែរនាសប្តាហ៍នេះ ។ អង្គជំនុំជម្រះ បានខិតខំប្រឹងប្រែងគួរឲ្យកត់សម្គាល់នៅក្នុងការធានាឲ្យកិច្ចដំណើរការនីតិវិធីប្រព្រឹត្តទៅបានលឿន និងល្អប្រសើរ ស្រប

ពេលដែលក្រុមមេធាវីការពារក្តីជនជាប់ចោទ **នួន ជា** ក៏បានព្យាយាមការពារសិទ្ធិកូនក្តីរបស់ពួកគេឲ្យទទួលបាននូវការគោរពសិទ្ធិស្មើៗគ្នាដូចភាគីដទៃទៀតនៃសំណុំរឿង ។

## *ជំពូកទី២ ៖* សេចក្តីសង្ខេបសក្ខីកម្មរបស់សាក្សី

សាក្សី **ខៀវ អេន** ជាអតីតកងជីវពលម្នាក់ មុនសម័យកម្ពុជាប្រជាធិបតេយ្យ និងក្រោយមក ក៏ក្លាយជាបុគ្គលិកម្នាក់ទទួលបន្ទុកផ្នែកចាប់ព័ត៌មានពីបរទេស ។ គាត់ត្រូវបានភាគីសួរចំៗ ទាក់ទងនឹងការដកមនុស្សចេញពីក្រសួងឃោសនាការ និងអប់រំ ក៏ដូចជាតួនាទីរបស់ជនជាប់ចោទ **នួន ជា** នៅក្រសួងនេះ ។ ដោយឡែក លោក **មាស វឿន** វិញ ធ្លាប់ជាមេបញ្ជាការរងកងពលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ គាត់បានផ្តល់ព័ត៌មានលម្អិតពីតួនាទីរបស់គាត់ក្នុងរបបនេះ ប្រព័ន្ធទំនាក់ទំនងផ្នែកយោធា និងរចនាសម្ព័ន្ធរដ្ឋបាល ។ គួរឲ្យកត់សម្គាល់ផងដែរថា សាក្សីរូបនេះ ក៏ត្រូវបានភាគីចោទសួរអំពីទំនាក់ទំនងរបស់គាត់ជាមួយនឹងជនជាប់ចោទ **ខៀវ សំផន** ផងដែរ ។

### ក. សក្ខីកម្មរបស់សាក្សី ខៀវ អេន

សក្ខីកម្មរបស់សាក្សី **ខៀវ អេន** បានចាប់ផ្តើមនៅព្រឹកថ្ងៃច័ន្ទ និងបានបញ្ចប់នៅរសៀលថ្ងៃអង្គារ។[2] សាក្សីបាននិយាយពីតួនាទីរបស់គាត់ ក្នុងនាមជាទាហាននៅក្នុងកងពលមួយរូប មុនរបបកម្ពុជាប្រធិបតេយ្យ និងបទពិសោធន៍របស់គាត់នៅក្នុងការចាប់ព័ត៌មានបរទេសនៅការិយាល័យ ក-៣៣[3] នៃក្រសួងឃោសនាការ និងអប់រំ ក៏ដូចជាការដឹងឮពីតួនាទីរបស់លោក **នួន ជា** ក្នុងក្រសួងនេះ ។

#### *ក.១. តួនាទី និងទំនួលខុសត្រូវរបស់លោក ខៀវ អេន*

##### *ក.១.ក. កងឈ្លបនៅស្រុកកំពង់លែង*

លោក **ខៀវ អេន** បានកើតនៅឆ្នាំ ១៩៥៨[4] ក្នុងស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង។ គាត់បានចូលរួមក្នុងចលនាបដិវត្តន៍នាឆ្នាំ១៩៧៣ ជាកងពលថ្នាក់ឃុំម្នាក់ ក្រោយពីការទម្លាក់គ្រាប់បែករបស់កងទ័ពអាមេរិកមកលើទឹកដីកម្ពុជា ដែលបានបំផ្លាញផ្ទះពី ៥០០ ទៅ៦០០ ខ្នង ហើយជាលទ្ធផលបន្សល់តែផ្ទះប្រហែល១០០ ខ្នងប៉ុណ្ណោះដែលនៅសេសសល់ ។[5] សាក្សីបានរៀបរាប់ពីការសម្រេចចិត្តរបស់គាត់ ក្នុងការចូលរួមចលនាតស៊ូដូចតទៅ៖

> *ប្រជាជនមកវិញនោះគឺថា ផ្ទះសម្បែងអីហ្នឹងវាអស់ ទាល់តែធ្វើខ្ទមអីនៅទាំងអស់ហ្នឹង ។ ហើយដល់ខ្ញុំហ្នឹង ការពិតទោះជាផ្ទះឆេះក៏មិន ជាការចង់ចូលធ្វើបដិវត្តន៍ទេ ។ ព្រោះដល់ឃើញអ៊ីចឹង កាន់តែពិបាកដល់ឪពុកម្តាយអីថែមទៀត ដែលអត់ផ្ទះអត់សម្បែង...សភាពការណ៍វាត្រូវបង្ខំយើងនៅអត់បាន ។*

សាក្សី ក៏បានរៀបរាប់ជាសង្ខេបអំពីការផ្សឹកព្រះសង្ឃថា បានចាប់ផ្តើមនៅពេលមានចលនាតស៊ូបដិវត្តន៍រីកដាលដល់ភូមិឋានរបស់គាត់នៅដើមទសវត្សរ៍ឆ្នាំ១៩៧០ ពោលគឺ"នៅមុនការចូលមកដល់នៃទាហាន **លន់ នល់**" ហើយនិងម្តងទៀត ពេលទាហាន **លន់ នល់** បរាជ័យ។[6]

សាក្សីបានពន្យល់ថា អ្នកភូមិមិនបានធ្វើការប្រឆាំងនឹងបញ្ជាឲ្យផ្សឹកព្រះសង្ឃទេ ។ គាត់បាននិយាយថា "គេឲ្យផ្សឹកព្រះសង្ឃឲ្យអី ក៏យើងមិនហ៊ានជំទាស់ហ៊ានអីដែរ។ គ្រាន់តែថា សភាពការណ៍ត្រូវផ្សឹក អាហ្នឹងខាងគេអ្នកផ្សឹក យើងជាប្រជាជនយើងអត់ហ៊ាននិយាយស្តីពីរឿងហ្នឹងទេ"។

នៅក្នុងខែមេសា ឆ្នាំ១៩៧៥ សាក្សី **ខៀវ អេន** ជាសមាជិកម្នាក់នៃកងវរសេនាតូចនៃស្រុកកំពង់លែង បានឈរជើង "ត្រៀមប្រយុទ្ធ" រហូតដល់ "ការរំដោះ"ភ្នំពេញ ។ ក្រោយថ្ងៃ១៧ មេសា ១៩៧៥ គាត់ត្រូវបានបង្គាប់ឲ្យចាត់ចែងផ្លាស់ទីអ្នករស់នៅទីក្រុងភ្នំពេញឲ្យទៅនៅសហករណ៍តាមឃុំមួយចំនួន។ ក្រោយមក អ្នកចំណូលថ្មីក្នុងឃុំត្រូវបានគេបង្ខំឲ្យជីកទំនប់ និងប្រឡាយទឹក។ សាក្សីបានរក្សាជំហរថា អ្នកចំណូលថ្មីដែលរស់នៅភូមិរបស់គាត់ គឺមានតែអ្នកមកពីទីប្រជុំជននានាពីតាមបណ្តាខេត្ត ហើយគាត់មិនបានដឹងអំពីប្រជាជនដែលត្រូវបានគេជម្លៀសមកពីភ្នំពេញទេ ។ សាក្សីចាំបានថា អ្នកភូមិគាត់បានហៅអ្នកចំណូលថ្មីថា "ប្រជាជន១៧ មេសា" ឬ "ប្រជាជនថ្មី" ។

### *គ.១.ខ. ការចាប់ព័ត៌មាននៅក្រសួងឃោសនាការ និងអប់រំ*

នៅចុងឆ្នាំ១៩៧៥ ឬ ដើមឆ្នាំ១៩៧៦ កងអនុសេនាធំរបស់សាក្សី **ខៀវ អេន** បានបញ្ជាគាត់ឲ្យចាកចេញពីខេត្តកំពង់ឆ្នាំង មកកាន់ភ្នំពេញវិញ ។ សាក្សីមិនបានដឹងថាអ្នកណាជាអ្នកចេញបញ្ជាចំពោះការផ្លាស់ប្តូរនេះទេ ប៉ុន្តែគាត់ចាំបានថា គាត់ជាបុគ្គលតែម្នាក់មកពីកងលេខ៣៣ ដែលត្រូវបានបញ្ជាឲ្យចាកចេញ ។ សាក្សីបានសង្កេតឃើញថា អ្នកធ្វើការនៅទីនោះ ត្រូវបានគេរើសពីវណ្ណៈថ្នាក់ក្រោម ចំណែកឯអ្នកចេះដឹងវិញ ខ្មែរក្រហមដូចជាមិនសូវចាប់អារម្មណ៍ទេ ។ គាត់មិនដឹងថាហេតុអ្វី ទើបគេជ្រើសរើសគាត់ឲ្យមកភ្នំពេញ ប៉ុន្តែគាត់បាននិយាយថា គាត់ "មិនមានអ្វីលាក់បាំងទេ" នៅក្នុងជីវប្រវត្តិរបស់គាត់ ។

នៅភ្នំពេញ គាត់ត្រូវបានគេនាំទៅក្រសួងឃោសនាការ និងព័ត៌មាន នៅទីនោះគាត់ត្រូវបានគេឲ្យធ្វើការក្រោមបញ្ជារបស់ "**បង ភាស់**" ឈ្មោះពិតត្រូវគាត់បានដឹងថាជា **ហ៊ូ នឹម** ។[7] នៅក្នុងក្រសួងនេះសាក្សី **ខៀវ អេន** បានធ្វើការក្នុងការិយាល័យ ក-៣៣ ក្រោមការគ្រប់គ្រងកូនរបស់ **ហ៊ូ នឹម** ឈ្មោះ **សាំ** ។[8] សាក្សី ត្រូវបាន"បណ្តុះបណ្តាលខាងជំនាញសារទូរលេខ និងចាប់ព័ត៌មាន" ។ ដំបូងឡើយ គាត់ត្រូវបានគេឲ្យជួសជុល "ម៉ាស៊ីនអង្គុលីលេខ" ជាលទ្ធផល គាត់ក៏បានរៀនពីរបៀបវាយសារទូរលេខ ។ ទោះជាយ៉ាងនេះក្តី សាក្សីបានអះអាងថា គាត់មិនបានយល់ពីខ្លឹមសារទូរលេខទេ ដោយនិយាយថា "រឿងខ្លឹមសារអីយល់យ៉ាងម៉េចៗ ខ្ញុំអត់ៗយល់ទេ ខ្ញុំយល់តែពីរឿងបច្ចេកទេសខ្ញុំធ្វើម៉េចឲ្យអក្សរហ្នឹងចេញក្រៅបានបញ្ជូនទៅបាន"ជាការស្រេច (តាមសាក្សីបានឲ្យដឹងថា ម៉ាស៊ីនចាប់ព័ត៌មានភាគច្រើននៅតាមបណ្តាប្រទេសជាក់ទូតគេមានប្រើ ហើយម៉ាស៊ីនទាំងនោះមិនត្រូវការអ្នកចេះវាយអត្ថបទបញ្ចូលដើម្បីបានព័ត៌មានទេ ពោលគឺវាអាចចាប់ព័ត៌មានបានតាមបែបទំនើប

ដោយគ្រាន់តែបញ្ជាបើកឲ្យវាដំណើរការ ដូច្នេះ ការវាយអត្ថបទតាម ព័ត៌មាននេះអាចធ្វើទៅបាន បន្ទាប់ពីយកខ្សែអាត់ថ៍ដែលបានពីការចាប់នេះ ទៅចាក់ក្នុងឧបករណ៍បន្លឺសំឡេង ទើបអាចវាយអត្ថបទតាមសំឡេងពីឧបករណ៍នោះ។ ក្រុមការងារគាត់ វាយចេញជាអត្ថបទ ហើយធ្វើជាខ្សែអាត់ថ៍សំឡេងនឹងយកទៅចាក់ផ្សាយវិញ) ។

ក្រោយមក លោក **ខៀវ អេន** ត្រូវបានគេឲ្យចាប់ព័ត៌មានពីបណ្ដាញព័ត៌មានអន្តរជាតិ រួមទាំង អា.អេហ្វ.ប៉េ (AFP) រ៉យទ័រ(Reuters) និង ស៊ីនហួរ (Xinhua) ដោយប្រើប្រាស់ "ម៉ាស៊ីនបញ្ជូនសារ" ដែលអាចវាយជាភាសាអង់គ្លេស និងភាសាបារាំង ហើយអាចចាក់ផ្សាយដោយខ្លួនវាបាន ។ តាមសាក្សីបានឲ្យដឹងថា ខ្លួនគាត់ផ្ទាល់រួមជាមួយនឹងបុគ្គលពីរនាក់ផ្សេងទៀត ព្រមទាំងមេគ្រប់គ្រងផ្ទាល់របស់គាត់ម្នាក់ឈ្មោះ **អុល** បានធ្វើការទាំងយប់ទាំងថ្ងៃ ដូរវេនគ្នាដើម្បីធានាឲ្យបានថាម៉ាស៊ីនបញ្ជូនសារមានដំណើរទៅមុខបានល្អ។ ដោយសារតែ ឯកសារចាប់បានពីម៉ាស៊ីន ជាភាសាអង់គ្លេស ឬជាភាសាបារាំង ហើយសាក្សីចេះតែភាសាខ្មែរ លោក **ខៀវ អេន** មិនបានយល់ពីព័ត៌មានដែលពួកគាត់ទទួលបាននោះទេ ។ ឯកសារចេញពីម៉ាស៊ីន ត្រូវបានបញ្ជូនចេញទៅ "ផ្នែកបញ្ជូន" ដែលមាននាទីចែកចាយព័ត៌មានទៅតាមផ្នែក និងអាជ្ញាធរមានសមត្ថកិច្ចតាមគោលដៅផ្សេងៗគ្នា ។ ក៏មានផ្នែកមួយដែលទទួលខុសត្រូវក្នុងការបកប្រែព័ត៌មានបរទេសទៅខ្មែរ និងផ្នែកមួយផ្សេងទៀតមានភារៈស្ដាប់ការផ្សាយដើម្បីផ្ទៀងផ្ទាត់បញ្ជាក់ថាឯកសារចេញពីម៉ាស៊ីនត្រឹមត្រូវ ។

សាក្សីបានរក្សាជំហរថា គាត់មានពេលដើម្បីផ្ដោតអារម្មណ៍តែលើការងារគាត់តែប៉ុណ្ណោះ ដូច្នេះ ខ្លួនមិនអាចឆ្លើយនឹងសំណួរទាំងឡាយណាដែលពាក់ព័ន្ធនឹងគោលដៅចុងក្រោយនៃឯកសារចេញពីម៉ាស៊ីនបញ្ជូនសារនោះទេ (ថាតើបុគ្គលដែលទទួលគឺជាអ្នកណា ឬឯកសារនោះត្រូវបញ្ជូនទៅណាក៏មិនដឹង) ។ តាមការយល់ដឹងរបស់គាត់ មិនមាននណាម្នាក់នៅក្នុងការិយាល័យរបស់គាត់មានសមត្ថភាពអាចធ្វើការទាក់ទងផ្ទាល់ជាមួយ "អង្គការ" ពីការចាប់ព័ត៌មានឡើយ ។

ចៅក្រម **ហ្សង់ម៉ាក ឡាវែន៍** បានសួរថាតើសាក្សីបានដឹងមានស្ថាប័នណាផ្សេងទៀត ដែលមានតួនាទីស្ដាប់ និងបញ្ជូនព័ត៌មានអន្តរជាតិ ។ លោក **ខៀវ អេន** បានឆ្លើយតបថា ជាផ្នែកមួយនៃការងាររបស់គាត់ គាត់បានទទួលម៉ាស៊ីនបញ្ជូនសារដែលខូចៗមួយចំនួនមកជួសជុល ដូច្នេះ គាត់សន្និដ្ឋានថា ប្រាកដជាមានស្ថាប័នមួយផ្សេងទៀត ដែលទទួលបន្ទុកចាប់ព័ត៌មាន ។

## *ក.២. ការចាប់ខ្លួនបុគ្គលិកនៅក្រសួងឃោសនាការ និងអប់រំ*

នៅពេលលោក **ខៀវ អេន** បានមកដល់ការិយាល័យ ក-៣៣ លើកដំបូងក្នុងឆ្នាំ១៩៧៥ សមមិត្ត **ហ៊ូ នឹម** គឺជារដ្ឋមន្ត្រីក្រសួងឃោសនាការ និងព័ត៌មាន ។ សាក្សីចាំបានថាសមមិត្ត **ហ៊ូ នឹម** ត្រូវបានគេដកពីតួនាទីរបស់គាត់ក្នុងឆ្នាំ១៩៧៧ តែគាត់មិនបានចាំលម្អិតពីការចាប់ខ្លួននោះទេ។[9] សាក្សីបានសម្គាល់ឃើញថា ក្រសួងអប់រំ និងក្រសួងឃោសនាការ និងព័ត៌មាន គឺជាក្រសួងពីរដាច់ដោយឡែកពីគ្នារហូតដល់ឆ្នាំ១៩៧៧ នៅពេលលោកស្រី **យុន យ៉ាត**[10] ត្រូវបានគាត់សន្និដ្ឋានថាជាអ្នកគ្រប់គ្រងក្រសួងទាំងពីរនេះ។ ក្រសួងទាំងពីរ ត្រូវបានគេច្របាច់បញ្ចូលគ្នាទៅជាក្រសួង

ឃោសនាការ និងអប់រំ។[11] ក្នុងកិច្ចប្រជុំមួយដែលដឹកនាំដោយលោកស្រី **យុន យ៉ាត** សាក្សីបានទទួលព័ត៌មានតាមរយៈកិច្ចប្រជុំនេះថា លោក **ហ៊ូ នឹម** ទើបតែបានសារភាពថាខ្លួនគាត់គឺជា ភ្នាក់ងារ **សេ.អ៊ី.អា** ។

បន្ទាប់ពីចាប់ខ្លួនលោក **ហ៊ូ នឹម** រួចមក បុគ្គលិកជាច្រើនត្រូវបានគេចាប់ខ្លួន និងផ្ទេរចេញពីក្រសួងនេះ។ យោងតាមសាក្សី អ្នកដែលត្រូវបានផ្ទេរចេញ គឺជាកម្មាភិបាលដែលមកពីភូមិភាគបូព៌ា ព្រោះគាត់ឮអ្នកខ្លះនិយាយថា លេខាភូមិភាគបូព៌ាមាន "បញ្ហា"។ ចំណែកក្នុងផ្នែករបស់លោក **ខៀវ អេន** វិញ ដោយសារគាត់មកពីភូមិភាគបស្ចិម ដូចនេះ គាត់ក៏ជាបុគ្គលតែម្នាក់គត់ដែលរក្សាតំណែងបាន។ ប្រការនេះហើយ ដែលសាក្សីត្រូវតែរ៉ាប់រងធ្វើការទាំងអស់ជំនួសសហការីមុនៗរបស់ខ្លួន។ ក្រោយពេលដែលលោកស្រី **យុន យ៉ាត** បានរកមនុស្សមកពីភូមិភាគនិរតីឲ្យធ្វើការតំណែងទាំងនោះ ការបាត់ខ្លួនក្នុងក្រសួងក៏ត្រូវបានបញ្ឈប់ ។

## *ក.៣. តួនាទីជនជាប់ចោទ នួន ជា នៅក្រសួងឃោសនាការ និងអប់រំ*

យោងតាមសាក្សី ជនជាប់ចោទ **នួន ជា** បានចូលខ្លួនមកមើលការខុសត្រូវការងារនៅក្នុងការិយាល័យ ក-៣៣ ចាប់ពីចុងឆ្នាំ១៩៧៨ រហូតដល់វៀតណាមវាយចូលនៅខែមករា ១៩៧៩ ។ ទោះបីជាដំណើរនៃសក្ខីកម្មរបស់លោក **ខៀវ អេន** បានបង្ហាញថា ជនជាប់ចោទ **នួន ជា** "ចូលមក" ឬ "កាន់កាប់" ការិយាល័យ ក-៣៣ ក៏ពិតមែន តែគាត់បានសារភាពថា គាត់មិនបានដឹងច្បាស់ទាំងស្រុងទេអំពីតួនាទីរបស់ លោក **នួន ជា** នៅក្រសួង ។ លោក **ខៀវ អេន** បានបញ្ជាក់ថា "ខ្ញុំគ្រាន់តែដឹងថា កាលដែលដក **ហ៊ូ នឹម** ហើយ **យុន យ៉ាត** ចូលមកទទួលបន្ទាប់ពី **ហ៊ូ នឹម** បាទ ។ តែដល់ផុតពី **យុន យ៉ាត** ហើយលោក **នួន ជា** គាត់ចូលមកជំនួសម្តង"។

សាក្សីបានផ្តល់សក្ខីកម្មថា មិនមានប្រជុំ ឬការប្រកាសជាផ្លូវការណាមួយ អំពីការផ្លាស់ប្តូរថ្នាក់ដឹកនាំពីលោកស្រី **យុន យ៉ាត** មកលោក **នួន ជា** នោះទេ ។ គាត់បានបន្ថែមថា ដំបូងឡើយ លោកស្រី **យុន យ៉ាត** នៅតែចេញចូលក្នុងក្រសួង ប៉ុន្តែការទៅមករបស់គាត់ បានថមថយបន្តិចម្តងៗរហូតដល់បញ្ឈប់ទាំងស្រុង ។ សាក្សីមិនអាចនិយាយឲ្យបានច្បាស់លាស់ទេថាតើលោកស្រី **យុន យ៉ាត** បានទៅធ្វើការនៅស្ថាប័នណាផ្សេង ក្រោយពីគាត់ឈប់ធ្វើការនៅក្រសួង ប៉ុន្តែគាត់គ្រាន់តែដឹងថាគាត់លែងបានឃើញលោកស្រី **យុន យ៉ាត** មានវត្តមាននៅក្នុងបរិវេណក្រសួង ។

សាក្សីចាំបានថា មានពេលមួយនោះ លោក **នួន ជា** បានចូលមកបន្ទប់ធ្វើការគាត់ នៅពេលព្រឹក គាត់បានសំឡឹង"មើលជុំវិញ" ហើយសួរថាតើបុគ្គលិកបានបរិភោគអាហារហើយ ឬនៅ ហើយបានហាត់ប្រាណឬអត់?។ មានម្តងម្កាល លោក **ខៀវ អេន** បានផ្ញើព័ត៌មានពីម៉ាស៊ីន**បញ្ជូនសារ**ឲ្យលោក **នួន ជា** តាមរយៈបុគ្គលិកដែលធ្វើការជិត "អាគារធំ" ជាអាគារដែលនៅក្បែរការិយាល័យលោក **នួន ជា** ។[12] សាក្សីក៏បានចង្អុលបង្ហាញផងដែរថា គាត់បានបញ្ជូនព័ត៌មានចេញពីម៉ាស៊ីនទូរពុម្ព ជូនទៅលោក **នួន ជា** បានពីរ ឬបីដងដែរ និងបាននិយាយថា "ប្រសិនបើខ្ញុំជួបគាត់ ខ្ញុំនឹងឲ្យគាត់"។ ក្រៅពីទំនាក់ទំនងនេះ សាក្សីបានជួបលោក **នួន ជា** ពេលដែលគាត់ត្រូវធ្វើការណែនាំនូវ

កិច្ចការអ្វីមួយ ហើយពេលខ្លះ ក៏បានឃើញដោយចៃដន្យ នៅពេលជនជាប់ចោទរូបនេះ កំពុងបរិភោគអាហារថ្ងៃត្រង់ ពេលគាត់មកដល់ ឬចេញពីក្រសួង ។ សាក្សីបានថ្លែងថា ខ្លួនមិនដែលបានចូលរួមក្នុង"កិច្ចប្រជុំធំៗ" ឬវគ្គរៀនសូត្រនយោបាយដែលមានលោក **នួន ជា** ជាអធិបតីទេ។ លោក **ខៀវ អេន** បានបន្តថ្លែងថា មិនមានឯកសារណាមួយមកពីថ្នាក់លើនៃក្រសួង ចូលមកកាន់ផ្នែកការងាររបស់គាត់ទេ ។

យោងតាមសាក្សី ស្ថានភាពរស់នៅក្នុងក្រសួង ជាពិសេសរឿងម្ហូបអាហារ មានការប្រសើរឡើងក្រោមការដឹកនាំរបស់លោក **នួន ជា** ។[13] សាក្សីក៏បានប្រាប់ផងដែរថា ជនជាប់ចោទបានហាមឃាត់គាត់ និងសហសេវិកដទៃទៀតមិនឲ្យប្រើពាក្យ "ប្រជាជន១៧មេសា ប្រជាជនថ្មី ប្រជាជនមូលដ្ឋាន ឬប្រជាជនចាស់" ក្នុងក្រសួងទេ ។

មេធាវីការពារអន្តរជាតិរបស់លោក **នួន ជា** គឺលោក **ហ្សាស្តើ ប៉ៅ** បានផ្ទៀងផ្ទាត់សាក្សីនឹងចម្លើយរបស់សាក្សីមុនម្នាក់ទៀត ឈ្មោះ **គីម វន**[14] ស្តីពីភាពមិនស៊ីចង្វាក់គ្នាជាមួយសក្ខីកម្មរបស់លោក **ខៀវ អេន** ត្រង់ចំណុចដែលមានការបរិយាយពីថ្នាក់ដឹកនាំក្នុងក្រសួង ។ លោកមេធាវី បានថ្លែងថា យោងតាម **គីម វន** លោកស្រី **យុន យ៉ាត** នៅតែកាន់កាប់ក្រសួងរហូតដល់ ១៩៧៩ ហើយលោក **នួន ជា** គ្រាន់តែមកក្រសួងម្តងម្កាលនៅពេលលោកស្រី **យុន យ៉ាត** អវត្តមាន ។ លោក **ខៀវ អេន** បានប្រកាន់ជំហរថា "អ្វីដែលគាត់ដឹងគឺថា **យុន យ៉ាត** បានឈប់ធ្វើការនៅក្រសួង ឃោសនាការនិងព័ត៌មាន"។ ទោះជាយ៉ាងនេះក្តី គាត់ក៏បានសារភាពថា លោក **គីម វន** ប្រហែលជាបានដឹងពីតួនាទីរបស់លោក **នួន ជា** ច្រើនជាងគាត់ដោយនិយាយថា "ខ្ញុំគិតថា លោក **គីម វន** ច្បាស់ជាបានដឹងច្រើនជាងខ្ញុំ ដោយសារតែលោក **នួន ជា** ប្រហែលជាមកលេងគាត់ច្រើនជាង"។ ជាងនេះទៅទៀត សាក្សីបានថ្លែងថា ដោយសារតែគាត់មិនធ្វើការក្នុងអាគារធំរបស់ក្រសួង គាត់មិនបានឃើញមនុស្សចេញចូលក្នុងអាគារធំនោះទេ ។

លោក **ខៀវ អេន** បានបញ្ជាក់ថា គាត់មិនអាចផ្តល់យោបល់ស្តីពីរចនាសម្ព័ន្ធនៃឋានានុក្រម ឬកិច្ចការរបស់ថ្នាក់ដឹកនាំបានទេ ពីព្រោះគាត់ដឹងតែធ្វើយ៉ាងណាបំពេញនូវកិច្ចការរបស់ខ្លួនពីអ្នកគ្រប់គ្រងផ្ទាល់ ហើយ "មិនបានដឹងពីការទំនាក់ទំនងរវាងថ្នាក់ដឹកនាំ និងថ្នាក់ដឹកនាំផ្ទាល់របស់គាត់ ហើយថ្នាក់ដឹកនាំមានប៉ុន្មានស្រទាប់ក្នុងរចនាសម្ព័ន្ធក្រសួង ក៏មិនបានដឹងដែរ"។

## *ក.៤. កិច្ចប្រជុំនៅក្រសួង*

សាក្សីចាំបានថា ជារៀងរាល់ថ្ងៃ គាត់នឹងត្រូវចូលរួមប្រជុំ ដឹកនាំដោយប្រធានផ្នែករបស់គាត់ ដើម្បីពិភាក្សាស្តីពីការជោគជ័យនៃសមទ្ធិផលចេញពីការិយាល័យគាត់ និងលើកទឹកចិត្តឲ្យបង្កើនប្រសិទ្ធភាពការងារឲ្យកាន់តែប្រសើរឡើង ។ ជារៀងរាល់ ១០ថ្ងៃម្តង គាត់នឹងចូលរួមប្រជុំទិតៀន និងស្វ័យទិតៀន ដែលការប្រជុំនេះតម្រូវឲ្យបុគ្គលិកទាំងអស់ថ្លែងសារភាពពីកំហុសរបស់ខ្លួន និងរិះគន់គ្នាទៅវិញទៅមកទៅលើការបំពេញការងារ និង "ទស្សនៈនយោបាយរៀងៗខ្លួន"។ លោក **ខៀវ អេន** បានពន្យល់ថា "ការប្រជុំនេះមែនទែនវាជាការលាងសម្អាតខ្លួនឯងហើយ អាស្អីដែលខ្លួនឯង

មានហើយសារភាពប្រាប់មហាជន”។ គាត់បានបន្តថា បើមានបុគ្គលណាម្នាក់ធ្វើខុសដោយមិនគោរពតាមការណែនាំត្រូវបានចាត់ទុកថា “អាសេរី” “ជនសេរី” អ្នកដែល “គ្មានវិន័យ”។ ទោះជាយ៉ាងនេះក្តី សាក្សីមិនបានដឹងពីវិធានការដែលបានចាត់ទៅលើប្រជាជន “សេរី” យ៉ាងណានោះឡើយ។ សាក្សីបដិសេធនូវព័ត៌មានមួយដែលថា ខ្លួនធ្លាប់បានចូលរួមកិច្ចប្រជុំ ឬចូលរួមក្នុងវគ្គសិក្សាក្រៅពីក្រសួងឃោសនាការ ។

### *ក.៥. ឥរិយាបថសាក្សី និងភាពគួរជឿជាក់បាន*

សាក្សី **ខៀវ អេន** បានឆ្លើយសំណួរទៅតាមការចងចាំរបស់គាត់ និងថែមទាំងបានប្រាប់ទៅភាគីចំៗនៅពេលមានសំណួរណា ដែលស្ថិតនៅក្រៅការយល់ដឹងរបស់គាត់។ ក្នុងសក្ខីកម្មទាំងមូលសាក្សីបានថ្លែងដដែលៗថា គាត់មិនបានចាប់អារម្មណ៍ពីកិច្ចការ ឬទំនួលខុសត្រូវនៃស្ថាប័ន ឬបុគ្គលផ្សេងទៀតនោះទេ ។ គាត់បានប្រៀបប្រដូចខ្លួនគាត់ក្នុងដំណាក់កាលពេលនោះថា គាត់គ្រាន់តែជាជម្រៀក ឬជាផ្នែកនៃម៉ាស៊ីន ដែលអាចដំណើរការនៅពេលមានអ្នកណាម្នាក់បើកកុងតាក់ “អញ្ចឹងហើយ ខ្ញុំគ្រាន់តែផ្តោតអារម្មណ៍លើការងាររបស់ខ្ញុំ” តែប៉ុណ្ណោះ ។ ដូច្នេះ គាត់បដិសេធឆ្លើយសំណួរមួយចំនួន ជាឧទាហរណ៍ ហេតុផលនៅពីក្រោយការផ្លាស់ប្តូរថ្នាក់ដឹកនាំនៅក្រសួងសំណួរស្តីពីគណៈអចិន្ត្រៃយ៍ និងពីគោលដៅនៃឯកសារ**ទូរពុម្ព** ដែលចេញពីការិយាល័យរបស់គាត់បន្ទាប់ពីត្រូវបានបញ្ជូនចេញទៅ “ផ្នែកបញ្ជូន”។

ចំណុចគួរឲ្យកត់សម្គាល់មួយគឺថា សំណួររបស់មេធាវី **ប៉ៅ** ដែលបានផ្ទៀញសក្ខីកម្មរបស់សាក្សី **ខៀវ អេន** ទៅនឹងសក្ខីកម្មរបស់សាក្សី **គីម វន** បានធ្វើឲ្យមានចម្ងល់ពីទំហំនៃការយល់ដឹងរបស់សាក្សី **ខៀវ អេន** ទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាលនៃក្រសួងឃោសនាការ និងអប់រំ (សូមមើលជំពូកទី២ ក.៣.) ។ សាក្សីក៏បាននិយាយផងដែរថា គាត់បានព្រមផ្តល់សម្ភាសន៍ដោយស្ម័គ្រចិត្ត បើទោះណាជាកន្លងមក គាត់ធ្លាប់បានប្រាប់ដោយបុគ្គលិកមកពីការិយាល័យសហចៅក្រមស៊ើបអង្កេតថា គាត់នឹង“មិនត្រូវគេកោះហៅឲ្យមកធ្វើសក្ខីកម្មដោយផ្ទាល់នៅចំពោះមុខតុលាការ” ទេ ។

## ខ. សក្ខីកម្មរបស់លោក មាស វឿន

លោក **មាស វឿន** ហៅ “ស្វាយវឿន” គឺជាសាក្សីដំបូងដែលបានមកផ្តល់សក្ខីកម្មទាក់ទងនឹងរចនាសម្ព័ន្ធយោធាដែលបានកំណត់នៅក្នុងវគ្គទី៣នៃករណី០០២/១។ សហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើការសួរដេញដោលទៅកាន់សាក្សី **មាស វឿន** អំពីបទពិសោធន៍របស់គាត់ ក្នុងនាមជាអតីតសមាជិកម្នាក់នៃកងទ័ពបដិវត្តន៍កម្ពុជាមុន និងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាទំនាក់ទំនងរបស់គាត់ជាមួយមេដឹកនាំកំពូលនៃរបបនេះ ។[15]

### *ខ.១.　　តួនាទី និងទំនួលខុសត្រូវមុនឆ្នាំ ១៩៧៥*

យោងតាមសាក្សី **មាស រឿន** បានឲ្យដឹងថា គាត់បានចូលរួមតស៊ូជាមួយចលនាបដិវត្តន៍ ជាសមាជិកនៃក្រុមយុវជនស្នេហាជាតិក្នុងឆ្នាំ១៩៦៨ ។ សាក្សីបានថ្លែងថា ខ្មែរក្រហម "បានអប់រំគេឲ្យគេស្គាល់ពីស្ថានភាពស្រុកទេស រឿងប្រទេសយើងខ្វះឯករាជ្យដោយសារអាណានិគមបារាំង ហើយសេដ្ឋកិច្ចដែលនៅក្រោមអាណានិគមបារាំងគ្រប់គ្រងទាំងអស់"។ ក្រោយពីនេះមក សាក្សីបានចាប់ផ្តើមបម្រើការងារជាអង្គរក្សតាមការពារកម្មាភិបាលថ្នាក់ខ្ពស់មួយចំនួន ដែលបានលាក់ខ្លួននៅក្នុងព្រៃធំៗក្នុងខេត្តកំពង់ស្ពឺ និងកំពង់ឆ្នាំង ។ កម្មាភិបាលថ្នាក់ខ្ពស់ទាំងនោះដែលសាក្សីបានអះអាង រួមមាន **វន វេត**[16] **តា សឿង**[17] **ហ៊ូ យុន**[18] **ហ៊ូ នឹម**[19] និង **ខៀវ សំផន** ។ ដល់ឆ្នាំ១៩៧០ សាក្សីបានក្លាយជាទាហានពេញសិទ្ធិក្នុងជួរកងទ័ពនៃភូមិភាគនិរតី ។ គាត់បានទទួលបញ្ជាផ្ទាល់ពីមេបញ្ជាការនៃកងពល១ ឈ្មោះ **តាសឿង** ។ ទោះជាយ៉ាងនេះក្តី យោងតាមសាក្សី លេខាភូមិភាគ **តា ម៉ុក** មានអំណាចច្រើនជាង ។ ក្នុងឆ្នាំ ១៩៧៣ **តា សឿង** បានតែងតាំងសាក្សី (**មាស រឿន**) ជាមេបញ្ជាការកងវរសេនាតូច ហើយនៅប៉ុន្មានឆ្នាំបន្ទាប់មកទៀត សាក្សីបានចូលរួមប្រយុទ្ធនៅជុំវិញផ្លូវជាតិលេខ ៥ និងក្នុង "តំបន់រំដោះ"ឧត្តុង្គ ។

ព្រះរាជអាជ្ញា **ចារីក អាប់ឌុលឡាក់** បានអានឯកសារមួយដែលបានសន្មតទុកថាបានថ្លែងឡើងដោយលោក **ខៀវ សំផន ហ៊ូ យុន** និង **ហ៊ូ នឹម** (ឯកសារ E 3/637) ។ ក្នុងឯកសារបានថ្លែងថា "យោតាមស្ថិតិ គឺយើងបានធ្វើការកម្ទេច និងធ្វើឲ្យឈ្លើយសឹករងរបួសចំនួន ១,០៥០នាក់ នៅសមរភូមិស្រុកបន្ទាយមាស និងនៅស្រុកព្រៃខ្មែរ ខេត្តកំពង់ឆ្នាំង តាមផ្លូវជាតិលេខ៥"។ សាក្សីបានទទួលស្គាល់នូវសុក្រឹតភាពនៃការរៀបរាប់ព្រឹត្តិការណ៍នាពេលនោះ។ ទាក់ទងនឹងស្ថានការណ៍នៅស្រុកឧត្តុង្គ សាក្សី **មាស រឿន** បាននិយាយថា គាត់មិនឃើញមានប្រជាជនរស់នៅក្នុងតំបន់នេះទេនៅពេលចូលមកដល់ ព្រោះប្រជាជនទាំងនោះបានចាកចេញទៅកាន់តំបន់រំដោះ ។ គាត់បាននិយាយថា "ខ្ញុំដឹងថាប្រជាជនមិនចង់ទៅ តែយើងត្រូវតែបង្ខំឲ្យចេញដើម្បីជៀសវាងគ្រោះថ្នាក់ពីការប្រយុទ្ធគ្នា"។ ពេលព្រះរាជអាជ្ញាព្យាយាមបញ្ជាក់ថាតើក្រុមគាត់ត្រូវបានគេបញ្ជាឲ្យរៀបចំផ្លាស់ទីប្រជាជនឬយ៉ាងណា? សាក្សីហាក់ដូចជាឆ្លើយផ្ទុយពីចម្លើយរបស់ខ្លួនមុននេះបន្តិច ដោយសាក្សីបាននិយាយថា "ទេ មិនមានបញ្ជាទេ ។ ប្រជាជនចេញដោយខ្លួនឯង"។

### *ខ.២.　　មេបញ្ជាការកងវរសេនាធំ៖ ការរំដោះទីក្រុងភ្នំពេញ និងសកម្មភាពបន្តបន្ទាប់*

មុនពេលដែលខ្មែរក្រហមបានវាយលុកចូលភ្នំពេញនៅខែមេសា ១៩៧៥ **តា សឿង** បានតែងតាំងសាក្សី **មាស រឿន** ជាមេបញ្ជាការកងវរសេនាធំ ។ នៅក្នុងមុខតំណែងមួយនេះ សាក្សី អាចបញ្ជាទាហានក្រោមបង្គាប់ខ្លួនបានប្រហែល ៦០០ នាក់ ខណៈដែលគាត់ខ្លួននៅតែបន្តទទួលបញ្ជាពី **តា ម៉ុក** តាមរយៈ **តា សឿង** ។ មុនពេលទទួលបានការឡើងឋានន្តរសក្តិ សាក្សី **មាស រឿន** បាន

ពន្យល់ថា បេក្ខជនត្រូវបានគេវាយតម្លៃលើភាពស្មោះត្រង់ និង "សកម្មភាពល្អ" ក្នុងសង្គម ។

### *៦.២.ក ការបញ្ជាឲ្យវាយលុកយកភ្នំពេញ*

ប្រហែលជាមួយសប្តាហ៍មុនការវាយលុកចូលភ្នំពេញ សាក្សីបានទទួលការណែនាំពីមេបញ្ជាការកងពលរបស់គាត់ឲ្យចូលរួមការប្រយុទ្ធ ។ លោក **មាស វឿន** បានទទួលខុសត្រូវដឹកនាំការវាយលុកពីត្រឹមពោធិ៍ចិនតុង ។ ក្នុងពេលប្រជុំត្រៀមវាយភ្នំពេញ សាក្សី **មាស វឿន** បានបញ្ជាក់ថា ខ្លួន "មិនបានមានឮផែនការថា អូ! ឈ្នះហើយនាំគ្នាប្រជុំរឿងជម្លៀសប្រជាជនអីនោះ ខ្ញុំបាទអត់បានឮក្នុងគម្រោងការគេប្រជុំនោះទេ"។ "សេនាធិការដ្ឋាន"ពីថ្នាក់លើ[20] បានរំពឹងថា "ការរំដោះ" ភ្នំពេញនឹងអាចធ្វើនៅថ្ងៃ ១៨ មេសា ១៩៧៥ ប៉ុន្តែជាក់ស្តែង កងកម្លាំងបានត្រៀមរួចជាស្រេច និងអាចរំដោះទីក្រុងបាននៅថ្ងៃទី ១៧ មេសា ពោលគឺមុនមួយថ្ងៃ ។ កងវរសេនាធំរបស់លោក **មាស វឿន** ក៏បានទទួលបញ្ជាពី"ថ្នាក់លើ"ផងដែរ ថាមិនឲ្យវាយប្រហារសត្រូវ ឬដៃគូប្រយុទ្ធរបស់ខ្លួនណាដែលលើកទង់ជ័យសឡើយ ។ សាក្សីបានពន្យល់ពីការណែនាំដែលបានទទួលពីថ្នាក់លើ ចំពោះការចាប់បានទាហាន **លន់ នល់** យ៉ាងដូច្នេះថា៖ "ពេលដែលចាប់ គឺបញ្ជូនទៅឲ្យខាងប្រធានកងពល ។ ប្រធានកងពលបញ្ជូនទៅណាទៀត អាហ្នឹង ខ្ញុំអត់បានដឹងទេ"។

សាក្សីបាននិយាយថា ប្រធានកងពល គឺចង់"សំដៅលើអ្នកដឹកនាំជាន់ខ្ពស់។ ដូចជា **តា ម៉ុក តា សុនសេន** ឡើងទៅ"។ បន្ទាប់មក ព្រះរាជអាជ្ញា **អាប់ឌុលឡាក់** បានសួរសាក្សីឲ្យបញ្ជាក់ថាតើអ្នកណា "នៅពីលើកម្រិតសេនាធិការទាំងនោះ? អ្នកណានៅពីលើ **តា ម៉ុក** និង **សុន សេន**?" សាក្សីបានឆ្លើយថា៖ "កាលនោះខ្ញុំបាទដឹងតែឈ្មោះ **សុន សេន តាម៉ុក** និងលោក **ខៀវ សំផន** ប៉ុណ្ណោះ"។

### *៦.២.ខ ការរំដោះ និងការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ*

លោក **មាស វឿន** បានចូលមកដល់ភ្នំពេញជាមួយកងទ័ពរបស់គាត់នៅព្រឹក ១៧ មេសា ១៩៧៥ ។ ពួកគេត្រូវបានទទួលបញ្ជាឲ្យវាយចូលទីបញ្ជាការទ័ពរបស់ **លន់ នល់** ។ ទោះបីជាកងវរសេនាធំរបស់គាត់មិនបានជោគជ័យ តែកងពលមកពីភូមិភាគឧត្តរ និងបូព៌ា ដែលបានវាយចូលភ្នំពេញមុនគាត់ បានវាយដល់ទីបញ្ជាការ **លន់ នល់** ដូចបានគ្រោងទុក ។ ពេលដែលសាក្សីត្រូវបានភាគីសួរពីស្ថានភាពនៅទីក្រុងនាពេលនោះ គាត់បានថ្លែងថា៖ "បាទ ក្នុងពេលដែលវើចូលទៅដល់ហើយ ឃើញនៅតាមផ្ទះថ្ម មានទង់ព៌ណសទាំងអស់ពេលនោះ ការផ្ទុះអាវុធអី ក៏ត្រូវស្ងាត់ទាំងអស់ បាទ"។ នៅថ្ងៃបន្ទាប់ សាក្សី **មាស វឿន** បានទទួលបញ្ជាពី **តា ម៉ុក** ឲ្យដកកម្លាំងទៅទិសខាងលិចស្ទឹងមានជ័យ ហើយប៉ុន្មានថ្ងៃក្រោយមក គាត់បានឃើញប្រជាជននាំគ្នាជម្លៀសចេញពីទីក្រុងតាមបណ្តោយផ្លូវជាតិលេខ ៣ និង ៤ ។ ទោះជាយ៉ាងនេះក្តី សាក្សីមិនបានដឹងពីថាមាន បទបញ្ជាឲ្យជម្លៀសប្រជាជននោះទេ ហើយក៏មិនបានដឹងថាតើផែនការនេះអនុវត្តរបៀបណាដែរ ។ នៅថ្ងៃ

ក្រោយ ១៧ មេសា គាត់បានឮពី **តា សឿង** ថាប្រជាជនដែលចេញពីភ្នំពេញ គឺចេញតែមួយសប្តាហ៍ទេ ដើម្បីកុំឲ្យមានការច្របូលច្របល់ជាមួយនឹងកងទ័ពសាធារណរដ្ឋ **លន់ នល់** ហើយកាលណារៀបចំស្រួលបួលហើយបានឲ្យប្រជាជនទាំងនោះចូលភ្នំពេញវិញ"។

### *ខ.២.គ. ការដកទ័ពចេញពីភ្នំពេញ*

តាមរយៈមេបញ្ជាការកងពលរបស់គាត់ លោក **មាស មឿន** បានទទួលការណែនាំពី **តា ម៉ុក** ឲ្យដកទ័ពចេញពីភ្នំពេញទៅកសិដ្ឋានមួយនៅស្រុកកំពង់ត្រាច ខេត្តកំពត។ នៅពេលមានការណែនាំនេះ ប្រជាជនកំពុងនៅតែជម្លៀសចេញពីភ្នំពេញ ។ សាក្សីបានឈរជើងនៅកំពតជាមួយទាហានរបស់គាត់រហូតដល់ចុងឆ្នាំ ១៩៧៦ ។ ការផ្លាស់ប្តូរទីតាំងនេះ គឺស្របតាមទំនួលខុសត្រូវរបស់កងទ័ព ។ លោក **មាស មឿន** បានពន្យល់ថា ៖ ក្នុងនាមជាកងទ័ព គឺមិនមែនគិតតែពីការប្រយុទ្ធតែមួយមុខនោះទេ ពោលគឺ "ដៃម្ខាងវ៉ៃខ្មាំង ដៃម្ខាងបង្កបង្កើនផល"។ នៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ សាក្សី និងទាហានប្រហែលជា ២,៧០០ នាក់ ត្រូវបានផ្លាស់ឲ្យទៅនៅខេត្តកោះកុង នៅក្នុងភូមិភាគបស្ចិម ។[21]

### *ខ.៣. អគ្គមេបញ្ជាការកងពលក្នុងភូមិភាគបស្ចិម៖ ១៩៧៧ - សីហា ១៩៧៨*

ក្រោយពេលការមកដល់របស់សាក្សីនៅខេត្តកោះកុង មេបញ្ជាការកងពលរបស់សាក្សី **មាស មឿន** គឺ **តា សឿង** និងលេខាភូមិភាគបស្ចិម **ជូ ជេត** បានតែងតាំងសាក្សីជាអគ្គមេបញ្ជាការនៃកងពលលេខ១ ។[22] ក្នុងមុខតំណែងនេះ សាក្សីត្រូវបានបញ្ជាឲ្យការពារឆ្នេរសមុទ្រកម្ពុជា ដោយប្រើប្រាស់នាវាទ័ពថ្មើរជើង បោះទីតាំងតាមកោះនានា និងតាមឆ្នេរសមុទ្រ ។ លោក **មាស មឿន** បានទទួលខុសត្រូវការពារកោះកម្ពុជានានាដែលនៅជិតព្រំដែនសមុទ្រ និងក្រុងកោះកុង ។ ចំណែកកោះដែលមានទីតាំងហួសទៅប៉ែកខាងត្បូង ជិតកំពង់សោមបានស្ថិតនៅក្រោមការគ្រប់គ្រងរបស់ កងពលលេខ ៣ ហើយ **តា មុត** (មាស មុត) ជាមេបញ្ជាការ ។ សាក្សីបានធ្វើការទាក់ទងជាមួយកងវរសេនាធំនៃកងពលលេខ ៣ តាមសារទូរលេខ ដើម្បីធានានូវភាពច្បាស់លាស់នៃការទទួលខុសត្រូវតាមកងពលរៀងៗខ្លួនកុំឲ្យជាន់គ្នា ។

### *ខ.៣.ក. ការចាប់អ្នកភៀសខ្លួនទៅថៃ*

មុនពេលសាក្សី **មាស មឿន** មកដល់ទឹកដីនៃខេត្តកោះកុង សាក្សីបានថ្លែងថាប្រជាជនត្រូវបានគេជម្លៀសចេញពីទីរួមខេត្តឲ្យទៅធ្វើកសិដ្ឋាននានានៅទីជនបទ ។ ចំពោះអ្នកដែលរស់នៅតាមកោះ ត្រូវបានគេបញ្ជូនឲ្យទៅតាម"មូលដ្ឋាន" ហើយមិនមានប្រជាជនរស់នៅតំបន់ឆ្នេរទេ ព្រោះទាហានបានបោះមូលដ្ឋានទ័ពឈរជើងការពារនៅតាមតំបន់ទាំងនេះ ។ មានពេលខ្លះ សាក្សី និងកូនទាហានរបស់គាត់ចាប់បានប្រជាជនមួយចំនួន ដែលប៉ុនប៉ងភៀសខ្លួនទៅប្រទេសថៃ ក៏ប៉ុន្តែ

ដោយសារគ្មានទូកសម្រាប់ពួកគាត់អាចធ្វើដំណើរឆ្លងសមុទ្របានប្រជាជនទាំងនោះ ជារឿយៗបានជ្រើសយកមធ្យោបាយដើរកាត់តាមព្រៃ ។ សាក្សី **មាស រឿន** បានថ្លែងថា ខ្លួនមិនបានទទួលការណែនាំជាក់លាក់ណាមួយឲ្យធ្វើការអន្តរាគមន៍ចំពោះអ្នករត់ភៀសខ្លួនទាំងនោះទេ "អត់មានបញ្ជាពីណាទេ ខ្ញុំឃើញថាបើដើរជួបគាត់ទៅ ក៏យកគាត់មក ហើយក៏រាយការណ៍មកកងពលមក កងពលគាត់ថាឲ្យបញ្ជូនគាត់មកខាងក្រោយមក យើងក៏បញ្ជូនមក"។ របាយការណ៍នេះ ត្រូវបានធ្វើឡើងតាមរយៈវិទ្យុទាក់ទង(តេអូ) និងតាមសារទូរលេខ ។ សាក្សីក៏បានបន្តផ្តល់សក្ខីកម្មថា កងពលបានប្រើប្រាស់មធ្យោបាយទំនាក់ទំនងតាមរយៈទូរលេខ ដើម្បីរាយការណ៍ និងទទួលបញ្ជាពីសេនាធិការដ្ឋាន ។[23]

### *ខ.៣.ខ. ការចាប់ឃាត់ទូកនេសាទថៃ និងវៀតណាម*

សាក្សីបានទទួលបញ្ជាឲ្យតតាំងជាមួយទាហានថៃនៅតាមបន្ទាត់ព្រំដែន ដើម្បីឆ្លើយតបទៅនឹងការឈ្លានពានមកលើដែនទឹកកម្ពុជាតាមរយៈការអនុញ្ញាតឲ្យមានទូកនេសាទថៃ ដែលបានប្រើឧបករណ៍ខុសច្បាប់ ។ លោក **មាស រឿន** បាននិយាយថាគាត់ ប្រាកដណាស់ថាបទបញ្ជាដែលគាត់បានទទួលពី **តា សឿង** ពេលនោះ គឺចេញមកពីថ្នាក់សេនាធិកាដ្ឋាន ។ បទបញ្ជាពីមេបញ្ជាការកងពល បានបញ្ជាឲ្យលោក **មាស រឿន** ចាប់ឃាត់ទូកថៃ ទុកតែមនុស្ស ហើយបញ្ជូនទូកទៅទីបញ្ជាការកងពលនៅកំពង់សោម ។[24] ចំណែកទូកវៀតណាម ដែលមានមនុស្សប្រុសស្រី និងក្មេងៗ ដែលបានព្យាយាមធ្វើដំណើរទៅប្រទេសថៃតាមផ្លូវទឹក ហើយត្រូវបានចាប់ខ្លួននៅដែនសមុទ្រកម្ពុជា ត្រូវបានចាត់ចែងដូចគ្នានឹងទូកថៃដែរ ។ សាក្សីមិនបានដឹងទេ ថាតើកងពលបានរាយការណ៍ពីការចាប់ខ្លួនទូកថៃ និងទូកវៀតណាម ក៏ដូចជាអ្នកធ្វើដំណើរតាមទូកទាំងនោះទៅឲ្យសេនាធិការដ្ឋាន ។

### *ខ.៣.គ ការដកកម្មាភិបាលមន្ទីរសន្តិសុខ និងកងកម្លាំងពិសេស*

សាក្សី **មាស រឿន** បាននិយាយថា នៅពេលដែលគាត់បានមកដល់ភូមិភាគបស្ចឹម គាត់បានឮពីទាហានក្នុងតំបន់និយាយពីការដកថ្នាក់ដឹកនាំមួយចំនួននៃតំបន់លេខ៣៧ (ប្រចាំខេត្តកោះកុង) រួមទាំងថ្នាក់លេខាធិការ និងមេទាហានផងដែរ។ សាក្សីបានថ្លែងថា "ក្រោយគេដកចេញពួកគេនោះ គេបានបញ្ជូនទៅភូមិភាគ តែខ្ញុំមិនដឹងហេតុផលអ្វីបានជា ដកអ្នកទាំងបីនោះចេញនោះទេ"។ លោក **មាស រឿន** បានបញ្ជាក់ថា នៅពេលគាត់និយាយពី"ភូមិភាគ" គឺចង់សំដៅទៅលើលេខាភូមិភាគបស្ចឹម **ជូ ជេត** ។ គាត់មិនដែលបានទៅទីនោះទេ តែគាត់បានដឹងឮព័ត៌មាននេះ ពីមន្ទីរសន្តិសុខកោះខ្យង ក្នុងស្រុកព្រៃនុប ។ ទាហានក្នុងកងពលលេខ១ ត្រូវបានស៊ើបអង្កេតពីខ្សែស្រឡាយជាប់ពាក់ព័ន្ធទៅនឹងមន្ត្រី និងទាហាននៃរបប **លន់ នល់** ។ ប្រសិនបើមានខ្សែស្រឡាយណាមួយដែលត្រូវបានគេរកឃើញនោះ **តា សឿង** នឹងហៅឲ្យមកជួប និងយកពួកគេទាំងនោះទៅ "មន្ទីរសន្តិសុខកោះខ្យង ឬកន្លែងផ្សេងទៀត" ។ សេចក្តីសម្រេចទាំងអស់ក្នុងការស៊ើបអង្កេត និងចាប់ខ្លួនមនុស្ស

នៅក្នុងកងពល ត្រូវបានធ្វើឡើងដោយអង្គភាពដាច់ដោយឡែកមួយ ដែលគ្រប់គ្រងដោយ **តា សឿង** ជាបុគ្គលម្នាក់ដែលសាក្សីបានមកពី"កងវរសេនាធំពិសេស" ឬ"កងពិសេស"។ លោក **មាស វឿន** ត្រូវបាន **តា សឿង** ណែនាំឲ្យរក្សាកំណត់ហេតុនៃប្រវត្តិរូប និងសកម្មភាពមុនៗ ក្នុងការបំពេញការងាររបស់ទាហានក្នុងកងពល ដើម្បីជួយដល់ការសម្រេចចិត្តរបស់គាត់ ។ លោក **មាស វឿន** បានពន្យល់ថា នៅពេល "កងពិសេស" មកយក និងដកទាហានគាត់ចេញទៅ គាត់មិនបានប្រឆាំងទេ ដោយបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួន ។ ព្រះរាជអាជ្ញាបានស្រង់នូវឯកសារចំនួនពីរ ពីការិយាល័យ ម-៤០១ ដែលសាក្សីបានអះអាងថា ជាការិយាល័យធ្វើការរបស់ **ដួ ជេត** ។[25] ឯកសារទាំងនេះ បានចុះឈ្មោះបុគ្គលដែលត្រូវបោសម្អាត ឬត្រូវ "កម្ទេច"ចោល ។[26] លោក **មាស វឿន** បានបញ្ជាក់ថា ភាគច្រើននៃអ្នកដែលត្រូវបានដកចេញពីកងពលលេខ១ គឺត្រូវបានចោទប្រកាន់ពីបទជាប់ខ្សែបណ្ដាញជាមួយ **សេ.អ៊ី.អា**(ចារកម្មអាមេរិក) ។

### *ខ.៤ ការស៊ើបអង្កេតនៅតំបន់ព្រះវិហារៈ សីហា ១៩៧៨ - មករា ១៩៧៩*

សាក្សី **មាស វឿន** បានថ្លែងថា ក្នុងខែសីហា ១៩៧៨ គាត់ត្រូវបានផ្លាស់ពីខេត្តកោះកុង ឲ្យទៅកាន់កាប់តំបន់មួយក្នុងខេត្តព្រះវិហារ ។ ក្នុងពេលធ្វើដំណើរ គាត់បានឈប់នៅភ្នំពេញ តាមបញ្ជារបស់ **តា សឿង** ដើម្បីចូលរួមកិច្ចប្រជុំមួយជាមួយ **ប៉ុល ពត** និងមេកងពលមួយចំនួនទៀត ។ សាក្សីបានបង្ហាញថា គាត់មិនបានជួបលោក **នួន ជា** ឬក៏លោក **ខៀវ សំផន** ទេ ។ ពេលនោះ **ប៉ុល ពត** បានរាយការណ៍ពីការវាយប្រហារតាមព្រំដែនវៀតណាម ព្រមទាំងស្ថានការណ៍ផ្សេងៗដែលបានកើតមានក្នុងតំបន់ព្រះវិហារ និងនៅខេត្តសៀមរាប ជាពិសេសទាក់ទងនឹងរឿងរ៉ាវដែលប្រជាជនត្រូវបានគេចាប់ខ្លួន និងបញ្ហាទុរ្ភិក្សរបស់ប្រជាជន ។ **ប៉ុល ពត** បានបន្តផ្ដល់បេសកម្មថ្មីមួយទៀតឲ្យសាក្សី និង **តា សឿង**[27] ឲ្យធ្វើការស៊ើបអង្កេតពីការដាក់គុកជនមួយចំនួននៅក្នុងខេត្តព្រះវិហារ និងសៀមរាប ។

#### *ខ.៤.ក សារទូរលេខ ការស៊ើបអង្កេត និងសាច់ញាតិរបស់ជនជាប់ចោទ ខៀវ សំផន*

សាក្សី **មាស វឿន** បានផ្ដល់សក្ខីកម្មថា មានឱកាសមួយនោះ ខ្លួន និងលោក **ខៀវ សំផន** បានធ្វើការទាក់ទងគ្នាតាមរយៈសារទូរលេខ។ ការទំនាក់ទំនងគ្នាដោយផ្ទាល់នេះ ចាប់ផ្ដើមឡើងដោយសារមានការស្នើសុំពីលោក **ខៀវ សំផន** ឲ្យសាក្សីជួយអន្តរាគមន៍ និងជួយផ្ដល់ព័ត៌មានពីស្ថានភាពសាច់ញាតិរបស់ជនជាប់ចោទរូបនេះ ក្នុងខេត្តព្រះវិហារ និងសៀមរាប ។ សាក្សីបានរកឃើញឪពុកម្ដាយក្មេករបស់លោក **ខៀវ សំផន** នៅក្នុងខេត្តព្រះវិហារ (តំបន់ ១០៣) ហើយបាននាំពួកគាត់ ឲ្យមកនៅក្នុងកងពលមួយនៃខេត្តសៀមរាប ព្រោះតែមានការព្រួយបារម្ភពីការចាប់ខ្លួន ។ ចំណែកឯស្ថានភាពនៅខេត្តសៀមរាប វិញ សាក្សី **មាស វឿន** បានចងចាំថា ខ្លួនបានរាយការណ៍ពីស្ថានភាពអ្នកជាប់ឃុំឃាំង និងក្រោយមកត្រូវបានដោះលែងដោយ **តា សឿង** ហើយក្នុងចំណោម

អ្នកដែលត្រូវបានដោះលែងទាំងនោះ ក៏មានបងប្អូនសាច់ថ្លៃរបស់លោក **ខៀវ សំផន** ផងដែរ។ សាក្សីក៏បានរកឃើញប្អូនស្រីថ្លៃរបស់លោក **ខៀវ សំផន** ក្នុងចំណោមអ្នកជាប់ឃុំឃាំងចំនួន ៧០០ នាក់ នៅមន្ទីរសន្តិសុខមួយក្នុងខេត្តសៀមរាប ។ សាក្សី និង **តា សឿង** បានចុះទៅមើលដល់មន្ទីរឃុំឃាំងនោះ ដើម្បីរំដោះគាត់ចេញ។ សាក្សីបានថ្លែងពីរបៀបចុះជួយរំដោះយ៉ាងដូច្នេះថា "បង **សឿង** គាត់ទៅទាក់ទងមុន ទើបបានខ្ញុំចូលទៅជាមួយគាត់ពេលក្រោយទៀត"។

ទាក់ទងនឹងការដាក់ឃុំឃាំងសាច់ញាតិរបស់លោក **ខៀវ សំផន** សាក្សីមិនដែលបានដឹងឡើយ ថាអ្នកណាបានបញ្ជាឲ្យមានការចាប់ឃុំនេះ ។ នាពេលនោះ សាក្សីក៏មិនបានដឹងច្បាស់ពីឋានៈរបស់លោក **ខៀវ សំផន** ដែរ ។ សាក្សីបានថ្លែងថា "តាមខ្ញុំដឹង គាត់កាន់តែតំបន់ ១០៣ ហ្នឹង គឺគាត់បានទទួលក្នុងតំបន់ ១០៣ ហ្នឹង តាមឮប្រជាជនគាត់ប្រាប់ខ្ញុំថា ជាតំបន់ស្វយ័ត ដោយលោក **ខៀវ សំផន** កាលហ្នឹងគេហៅថា អ៊ំ **ខៀវ សំផន** ហើយនិង អ៊ំ **នួន ជា**"។ សាក្សីបានបញ្ជាក់ថា គាត់ធ្វើតាមការណែនាំរបស់លោក **ខៀវ សំផន** ព្រោះគាត់ត្រូវបានគេប្រាប់ថាតំបន់១០៣ គឺស្ថិតក្រោមការគ្រប់គ្រងរបស់លោក **ខៀវ សំផន** ។

### *ខ.៥ ទំនាក់ទំនងជាមួយជនជាប់ចោទ*

សាក្សី **មាស វឿន** មិនបាននិយាយអ្វីពាក់ព័ន្ធនឹងជនជាប់ចោទ **អៀង សារី** ឡើយនៅក្នុងសក្ខីកម្មរបស់គាត់នាសប្តាហ៍នេះ ។ ទាក់ទងនឹងជនជាប់ចោទ **នួន ជា** វិញ សាក្សីបានថ្លែងថា តាំងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ គាត់មិនដែលបានឃើញលោក **នួន ជា** ទាំងនៅក្នុងកិច្ចប្រជុំ ឬនៅសមាជបក្សធំៗពីរលើក ដែលគាត់ធ្លាប់បានចូលរួម ។ សាក្សីក៏បានថ្លែងយោបល់ថា "ខ្ញុំអត់ដឹងថាគាត់កាន់តួនាទីរបស់គាត់យ៉ាងណាទេ ពីព្រោះខ្ញុំអត់បានដឹងថាគាត់ទទួលខាងអី ខ្ញុំមិនបានដឹងកិច្ចការងាររបស់ថ្នាក់ដឹកនាំរបស់មជ្ឈឹម"ទេ ។ ការឆ្លើយដូចនេះ គឺមិនស្របនឹងចម្លើយដែលគាត់បានឆ្លើយពីមុនជាមួយសហចៅក្រមស៊ើបអង្កេតឡើយ ។ នៅក្នុងសេចក្តីថ្លែងការណ៍របស់សាក្សី **មាស វឿន** ដែលបានផ្តល់ឲ្យសហចៅក្រមស៊ើបអង្កេត សាក្សីធ្លាប់ថ្លែងថា មានកិច្ចប្រជុំមួយ ដែលបានធ្វើឡើងជាមួយថ្នាក់សេនាធិការដ្ឋានមុនពេលរំដោះភ្នំពេញ ហើយកិច្ចប្រជុំនេះចូលរួមដោយ **សុន សេន** និងលោក **នួន ជា** ។ ទោះជាយ៉ាងនេះក្តី សក្ខីកម្មគាត់នៅក្នុងបន្ទប់តុលាការ សាក្សីបានបញ្ជាក់ថា គាត់គ្រាន់តែបានដឹងព័ត៌មាននេះពីមេបញ្ជាការកងពលរបស់គាត់ **តា សឿង** តែប៉ុណ្ណោះ ដោយសារគាត់មិនបានចូលប្រជុំផ្ទាល់នោះទេ ។

យោងតាមសក្ខីកម្ម សាក្សីបានមានទំនាក់ទំនងផ្ទាល់ជាមួយជនជាប់ចោទ **ខៀវ សំផន** ច្រើនជាងគេ។ ក្នុងអំឡុងពេលធ្វើសកម្មភាពបដិវត្តន៍ដំបូងនៅក្នុងព្រៃ សាក្សីក៏ធ្លាប់បានធ្វើជាអង្គរក្សការពារឲ្យលោក **ខៀវ សំផន** ដែរ ។ ទោះជាយ៉ាងណាក៏ដោយ សាក្សីបានដឹងតិចតួចពីតួនាទីរបស់ជនជាប់ចោទរូបនេះ ដោយគ្រាន់តែនិយាយថា គាត់បានឮថាជនជាប់ចោទ "ទទួលខុសត្រូវខាងសេដ្ឋកិច្ច" និងក៏ជាប្រធាននៃរណសិរ្សរួបរួមជាតិកម្ពុជា។ នៅពេលដែលសាក្សីបានមកដល់ខេត្តព្រះវិហារ កាលពីពាក់កណ្តាលឆ្នាំ១៩៧៨ លោក **មាស វឿន** បានចាប់ផ្តើមមានទំនាក់ទំនងជាថ្មី

ជាមួយលោក **ខៀវ សំផន** តាមរយៈសារទូរលេខ ប៉ុន្តែសាក្សីនៅតែមិនបានដឹងពីតួនាទីរបស់លោក **ខៀវ សំផន** ទាំងស្រុងនោះទេ កាលពីអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សាក្សី គ្រាន់តែបានដឹងថា លោក **ខៀវ សំផន** មានការជាប់ពាក់ព័ន្ធជាមួយតំបន់ស្វយ័ត១០៣ ។

### *ខ.៦ ឥរិយាបថសាក្សី និងភាពគួរជឿជាក់បាន ១៩៧៩*

សាក្សី **មាស វឿន** ហាក់ដូចជាមានភាពលាក់លៀមក្នុងការឆ្លើយតបទៅនឹងសំណួរពីភាគីព្រះរាជអាជ្ញា និងពីក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ នៅចុងបញ្ចប់នៃសក្ខីកម្មរបស់គាត់នៅថ្ងៃទីមួយ សាក្សីស្ទើរតែសម្រាន្តលក់ ដែលនេះប្រហែលបណ្តាលមកពីភាពហេវហត់ ប៉ុន្តែវាមិនបានប៉ះពាល់ដល់ចម្លើយរបស់គាត់ទេ ។ គាត់បានផ្តល់ចម្លើយលម្អិតអំពីឋានន្តរស័ក្តិកម្លាំងទ័ពនៃកម្ពុជាប្រជាធិបតេយ្យតាមលំដាប់លំដោយ និងបានជួយបញ្ជាក់នូវការយល់ខុសពីចម្លើយមុនៗរបស់គាត់ ដែលបានផ្តល់ទៅឲ្យសហចៅក្រមស៊ើបអង្កេត ។

## *ជំពូកទី៣ ៖* **បញ្ហាផ្លូវច្បាប់ និងនីតិវិធី**

សប្តាហ៍នេះ គឺជាសប្តាហ៍ដំបូងនៃការចាប់ផ្តើមសវនាការវគ្គទី៣នៃករណី ០០២/០១ តាមរយៈការអានកថាខណ្ឌពាក់ព័ន្ធ ដែលមានក្នុងដីកាដំណោះស្រាយ ហើយបន្ទាប់មកបានស្តាប់សក្ខីកម្មរបស់អតីតមន្ត្រីយោធាម្នាក់ ។ អង្គជំនុំជម្រះក៏បានពើបប្រទះនឹងការជជែកតវ៉ាលើបញ្ហានៃការប្រើប្រាស់ឯកសារដែលទទួលបានពីការធ្វើទារុណកម្ម និងរបៀបក្នុងការបង្ហាញភស្តុតាងថ្មីផងដែរសប្តាហ៍នេះ។ ដោយសារភាពមិនទៀងទាត់នៃស្ថានភាពសុខភាពរបស់ជនជាប់ចោទ **អៀង សារី** អង្គជំនុំជម្រះ បានស្តាប់ការដាក់សំណើរបស់ភាគី ថាតើនឹងត្រូវរៀបចំដំណើរការឆ្ពោះទៅមុខរបៀបណាដើម្បីកុំឲ្យមានការពន្យារពេល ។

### ក. **ការចាប់ផ្តើមវគ្គទី៣នៃសំណុំរឿង០០២/០១**

ជាកិច្ចចាប់ផ្តើមវគ្គទី៣នៃសំណុំរឿង០០២/០១ អង្គជំនុំជម្រះ បានបង្គាប់ឲ្យក្រុមក្រឡាបញ្ជីអានកថាខណ្ឌនៃដីកាដំណោះស្រាយម្នាក់បន្ទាប់ពីម្នាក់ដែលការអាននៃអង្គហេតុទាំងនោះ គឺពាក់ព័ន្ធនឹងរចនាសម្ព័ន្ធយោធានៅក្នុងកម្ពុជាប្រជាធិបតេយ្យ និងការផ្លាស់ទីប្រជាជន។[28] កិច្ចដំណើរការនេះ បានចាប់ផ្តើមនៅមុនពេលសម្រាកថ្ងៃអង្គារ និង បានបន្តនៅព្រឹកថ្ងៃពុធ ។ នៅក្នុងរចនាសម្ព័ន្ធយោធា កឋាខ័ណ្ឌនានាក្នុងដីកាដំណោះស្រាយដែលក្រឡាបញ្ជីបានអាន គឺក្តោបលើអង្គហេតុនៃៈ "ការបង្កើតកងទ័ពបដិវត្តន៍កម្ពុជា" "តួនាទីកងទ័ពបដិវត្តន៍កម្ពុជា" "អង្គភាពយោធារបស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា" "សមាសភាពកងទ័ពបដិវត្តន៍កម្ពុជា" "ការធ្វើទំនាក់ទំនង/ព័ត៌មាន" "ការប្រតិបត្តិវិន័យ" និង "ការចូលរួមរបស់កងបដិវត្តន៍កម្ពុជាក្នុងការបោសសម្អាត"។[29] ក្រឡាបញ្ជីក៏បានអានផ្នែកនៃដីកាដំណោះស្រាយ "កត់សម្គាល់អំពីអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម"[30] រួមបញ្ចូល

ទាំងកថាខ័ណ្ឌមួយចំនួនពាក់ព័ន្ធនឹងការផ្លាស់ទីប្រជាជន។[31]ដូច្នេះ កថាខ័ណ្ឌទាក់ទងនឹងការផ្លាស់ទីប្រជាជនវគ្គទី១[32] និងវគ្គទី២[33] "កត់សម្គាល់អំពីអង្គហេតុនៃឧក្រិដ្ឋកម្ម" ក៏ត្រូវបានអានដែរ។[34] ជាកិច្ចចុងក្រោយ ក្រឡាបញ្ជីបានអានកថាខណ្ឌខ្លះនៃដីកាដំណោះស្រាយ សំដៅទៅលើជនជាប់ចោទ **នួន ជា**[35] ជនជាប់ចោទ **អៀង សារី**[36] និងជនជាប់ចោទ **ខៀវ សំផន**[37] ។ បន្ទាប់ពីអានចប់ អង្គជំនុំជម្រះ បានកោះហៅសាក្សីទី១ គឺសាក្សី **មាស វឿន** ដើម្បីផ្តល់នូវអង្គហេតុនានាទាក់ទងនឹងសវនាការវគ្គទី៣នៃសំណុំរឿង០០២/០១ ។

ឆ្លើយតបនឹងការស្នើសុំឲ្យមានការពន្យល់ ដែលធ្វើដោយមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោក **ពេជ អង្គ** ប្រធានចៅក្រម **និល ណុន** បានថ្លែងថា កថាខណ្ឌនៅលេខរៀង ២៨២[38] នៃដីកាដំណោះស្រាយមិនត្រូវបានអនុញ្ញាតឲ្យអាន ព្រោះអង្គជំនុំជម្រះ "បានជម្រាបជូនរួចហើយ ថាឲ្យអាននូវកថាខណ្ឌទាំងឡាយ ដែលជាអង្គហេតុចោទប្រកាន់លើជនជាប់ចោទ"។ យោងតាមប្រធានតុលាការ ការអនុវត្តនេះ ស្របតាមឯកសារ E124/7.2 ("បញ្ជីកថាខណ្ឌ និងផ្នែកនានាដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿង ០០២ ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេច អំពីបញ្ហាសម្បទារបស់លោកស្រី **អៀង ធីរិទ្ធ** ក្នុងការចូលរួមសវនាការ E138") ។[39]

ក្រោយពីការអានកថាខណ្ឌពាក់ព័ន្ធនៃដីកាដំណោះស្រាយនៅថ្ងៃពុធ មេធាវីអន្តរជាតិការពារក្តីលោក **នួន ជា** គឺលោក **អេនឌ្រូ អ៊ីនូហ្ស៊ី** បានជូនព័ត៌មានដល់អង្គជំនុំជម្រះថា កូនក្តីខ្លួនមានបំណងចង់ធ្វើការកត់សម្គាល់ជាសាធារណៈអំពីសម្រង់មួយចំនួននៃដីកាដំណោះស្រាយ ដែលទើបតែអានដោយក្រឡាបញ្ជី ។ ប្រធានតុលាការបានតបវិញថា "អង្គជំនុំជម្រះនឹងពិចារណាសម្រេចនៅពេលសមស្របខាងមុខនេះ"។ បន្ទាប់ពីមេធាវី **អ៊ីនូហ្ស៊ី** បានព្យាយាមសុំឲ្យមានការបញ្ជាក់ជាម្តងហើយម្តងទៀតចំពោះសេចក្តីសម្រេចរបស់ប្រធានតុលាការទៅលើសំណើនេះ នៅថ្ងៃព្រហស្បតិ៍ ប្រធានតុលាការបាននិយាយថា អង្គជំនុំជម្រះនឹងពិចារណាអនុញ្ញាតិឲ្យជនជាប់ចោទ **នួន ជា** ធ្វើការកត់សម្គាល់របស់គាត់បាន បន្ទាប់ពីតុលាការស្តាប់នូវសក្ខីកម្មរបស់សាក្សី **មាស វឿន** ចប់សព្វគ្រប់សិននោះ អង្គជំនុំជម្រះនឹងចាត់ចែងពេលវេលាសម្រាប់ជនជាប់ចោទធ្វើការកត់សម្គាល់ ។ ប្រធានតុលាការបាននិយាយថា ការសម្រេចនេះ វាច្បាស់លាស់គ្រប់គ្រាន់ "សម្រាប់យល់ហើយ សូម្បីតែមនុស្សធម្មតា និងសម្រាប់មនុស្សមានហេតុផល"។ ជាការឆ្លើយតប មេធាវី **អ៊ីនូហ្ស៊ី** បាននិយាយថា "ខ្ញុំពិតជាមិនមែនជាមនុស្សមានហេតុផលទេ លោកប្រធាន"។

## ខ. ការដាក់ភស្តុតាងថ្មី

មុនពេលកោះហៅសាក្សី **មាស វឿន** មកកាន់សវនាការ ប្រធានតុលាការ **និល ណុន** បានធ្វើសេចក្តីសម្រេចបដិសេធលើសំណើរបស់សហព្រះរាជអាជ្ញា ដែលបានស្នើសុំដាក់ឯកសារថ្មីបញ្ចូលទៅក្នុងសំណុំរឿង (កិច្ចសម្ភាសន៍មួយរបស់សាក្សី កាលបរិច្ឆេទ ១១ ធ្នូ ២០១០) ។ លោកប្រធានបាននិយាយថា អនុលោមតាមវិធានផ្ទៃក្នុងលេខ ៨៧(៤) អង្គជំនុំជម្រះនឹងទទួលយកនូវភស្តុតាង

ថ្មី ដែលមានប្រយោជន៍ក្នុងការស្វែងរកការពិត ហើយដែលភស្តុតាងនោះមានការបង្ហាញជាបឋមនៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន យថាភាពនៃភស្តុតាង ក្រោមវិធាន ៨៧(៣) ។ យោងតាមវិធានផ្ទៃក្នុងលេខ ៨៧(៤) ជាទូទៅ អង្គជំនុំជម្រះ តម្រូវឲ្យភាគីធ្វើការស្នើសុំទៅកាន់អង្គជំនុំជម្រះ ដោយបង្ហាញពីមូលហេតុអ្វីខ្លះនាំឲ្យភស្តុតាងដែលចង់ដាក់ថ្មីនេះ មិនអាចរកបានមុនពេលការចាប់ផ្តើមការជំនុំជម្រះ និង/ឬ មិនអាចរកឃើញ ទោះបីជាមានការបំពេញការងារដោយយកចិត្តទុកដាក់ក៏ដោយ ។ ទោះជាយ៉ាងណាក្តី ប្រធានតុលាការបាននិយាយថា បើសង្កេតមើលទៅលើកាលបរិច្ឆេទឯកសារថ្មីស្តីពីកិច្ចសម្ភាសន៍នេះ ឃើញថាវាអាចនឹងឲ្យភាគី ជាពិសេសព្រះរាជអាជ្ញាផ្ទាល់ដែលជាភាគីស្នើគួរតែអាចរកបានអស់រយៈពេលជិតមួយឆ្នាំមកហើយ ចាប់តាំងពីពេលដែលអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគី នៅថ្ងៃ ២៥ តុលា ២០១១ ដែលថាលោក **មាស រឿន** អាចនឹងត្រូវបានកោះហៅឲ្យមកធ្វើសក្ខីកម្ម (មានន័យថា បើភាគីបានដឹងថាមានឯកសារពាក់ព័ន្ធនឹងសាក្សីជាក់លាក់ណាមួយដែលនឹងត្រូវមកផ្តល់សក្ខីកម្ម ភាគីនោះគួររៀបចំឲ្យបានស្រេចបាច់តាំងពីពេលនោះមកម្ល៉េះ) ។ ជាងនេះទៅទៀត ឯកសារកិច្ចសម្ភាសន៍ប្រមាណជា ៤០ទំព័រនេះ អាចរកបានតែជាភាសាខ្មែរតែប៉ុណ្ណោះ (ថ្ងៃសុក្រ សប្តាហ៍មុន ២៨ កញ្ញា ២០១២) ។ ទាំងនេះ បានផ្តល់ព័ត៌មានមិនគ្រប់គ្រាន់សម្រាប់ភាគី និងអង្គជំនុំជម្រះ (ចម្រុះជាតិសាសន៍ និងមានបីភាសាផ្លូវការ) ក្នុងការគិតពិចារណាទៅលើខ្លឹមសារនៃឯកសារដែលចង់ដាក់ក្នុងសំណុំរឿង ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធនូវការស្នើសុំរបស់សហព្រះរាជអាជ្ញា។

## គ. ការដកចេញនូវចម្លើយដែលទទួលបានដោយការធ្វើទារុណកម្ម

មុនពេលសម្រាកអាហារថ្ងៃត្រង់នៅថ្ងៃពុធ មេធាវី **អ៊ីនូហ្ស៊ី** បានធ្វើសំណើផ្ទាល់មាត់ និងនៅមុនពេលអង្គជំនុំជម្រះចាប់ផ្តើមធ្វើសវនាការ (in limine)[40] ដោយគាត់សុំឲ្យដកចេញ ឬគូសចោលនូវសំណួរ និងចម្លើយពីលេខរៀងទី១៦ ដល់ ២០ របស់លោក **មាស រឿន** ដែលបានឆ្លើយទៅកាន់សហចៅក្រមស៊ើបអង្កេត (ឯកសារ E3/40) ពីព្រោះក្នុងពេលសម្ភាសន៍ បុគ្គលិកផ្នែកស៊ើបអង្កេតបានសួរសំណួរទាក់ទងនឹងចម្លើយសារភាពពីមន្ទីរ ស-២១ របស់អតីតកម្មាភិបាល **ឌុ ជេត** ហៅ "ស៊ី"។[41]

មេធាវី **អ៊ីនូហ្ស៊ី** បានបកស្រាយថា អ្នកស៊ើបអង្កេតបានដកស្រង់ និងប្រើប្រាស់ផ្នែកសំខាន់នៃ "ឯកសារដែលបានមកពីការធ្វើទារុណកម្ម" ដែលផ្ទុយនឹងអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តដ៏ឃោរឃៅ អំពើអមនុស្សធម៌ ឬការធ្វើឲ្យថោកទាប ឬការដាក់ទណ្ឌកម្ម ។[42] ប្រធានតុលាការបានឆ្លើយតបថា អង្គជំនុំជម្រះបានកត់សម្គាល់សំណើនេះហើយ ។ ទោះបីជាមេធាវី **អ៊ីនូហ្ស៊ី** បានបកស្រាយថា សំណើនេះ គឺមិនបានវាយប្រហារលើកំហុសនីតិវិធីនៃការស៊ើបអង្កេតក្តី ក៏អង្គជំនុំជម្រះបានកត់សម្គាល់ថា មេធាវីមានសិទ្ធិសួរដេញដោលលើបញ្ហានីតិវិធីទាក់ទងនឹងការស៊ើបអង្កេតបែបនេះ ។ ភ្លាមៗបន្ទាប់ពីថ្លែងចប់ លោកប្រធានបានប្រកាសសម្រាក។

ក្នុងពេលចាប់ផ្តើមសវនាការនារសៀលនៃថ្ងៃដដែលនេះ ចៅក្រម **ស៊ីលវៀ ខាត់វ៉ាយថ៍** បានថ្លែងថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចដោយជាប់លាប់ និងដោយឯកច្ឆ័ន្ទថា រាល់ចម្លើយសារភាពដែលទទួលបានផ្ទុយនឹងអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម គឺមិនត្រូវបានទទួលឲ្យយកមកប្រើប្រាស់ជាឯកសារភស្តុតាង ឬជាមូលដ្ឋានសម្រាប់ការតាំងសំណួរឡើយ ។ បន្ទាប់មក ចៅក្រម **ខាត់វ៉ាយថ៍** បានបន្តទៀតថា អង្គជំនុំជម្រះនឹងមិនអនុញ្ញាតឲ្យសួរសំណួរទៅលើខ្លឹមសារនៃចម្លើយសារភាពរបស់កម្មាភិបាល **ជូ ជេត** ហើយក៏នឹងមិនប្រើប្រាស់ចម្លើយទាំងនេះជាសម្អាងក្នុងសេចក្តីសម្រេចសាលក្រមណាមួយដែរ ។ ថ្លែងឡើងដោយចំពោះ មេធាវី **អ៊ីនូហ្ស៊ី** ចៅក្រម **ខាត់វ៉ាយថ៍** បាននិយាយថា គោលការណ៍ច្បាប់ដែលយើងប្រើប្រាស់នោះ គឺមិនតម្រូវឲ្យលុបចេញនូវចម្លើយទាំងនោះទេ ដូច្នេះវាមិនមែនជាដំណោះស្រាយដ៏ម៉ឺងម៉ាត់មួយ ដែលអាចឲ្យអង្គជំនុំជម្រះយកមកធ្វើការពិចារណាឡើយ។ លោកស្រីបានបញ្ចប់ដោយនិយាយថា អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យភាគីធ្វើសំណើបន្ថែមទៀតទេលើបញ្ហានេះ ។

ប្រធានតុលាការ លោកចៅក្រម **និល ណុន** បានធ្វើការកត់សម្គាល់ថា បញ្ហានេះគួរតែត្រូវបានលើកយកមកដេញដោល "តាំងពីដំណាក់កាលស៊ើបអង្កេតឯណោះ ពោលគឺមុនពេលចេញដីកាដំណោះស្រាយ"។

ជាការឆ្លើយតប មេធាវី **អ៊ីនូហ្ស៊ី** បានថ្លែងថា នេះមិនមានជាបញ្ហាចោទទេ ចំពោះការដែលមេធាវីក្រុមខ្លួនអាចធ្វើទៅបានក្នុងដំណាក់កាលស៊ើបអង្កេត ឬអត់នោះ ប៉ុន្តែវាជាសំណើរបស់យើងស្នើឲ្យមានការដកចេញ ឬក៏កាត់បន្ថយនូវផ្នែកណាមួយដែលមានភាពមិនប្រក្រតី ហើយមានភាពពាក់ព័ន្ធជាមួយនឹងសាក្សីជាក់លាក់ ដែលអង្គជំនុំជម្រះបានកោះហៅឲ្យមកផ្តល់សក្ខីកម្ម។ លោកប្រធានតុលាការ បានរម្លឹកមេធាវី **អ៊ីនូហ្ស៊ី** ដូច្នេះថា អង្គជំនុំជម្រះបានសម្រេចរួចហើយពីបញ្ហានេះ ។ ភ្លាមៗនោះបន្ទាប់ពីថ្លែងចប់ លោកប្រធានក៏ប្រកាសហៅឲ្យនាំខ្លួនសាក្សី **មាស វឿន** មកកាន់សវនាការ ។

## ឃ. សំណើពីភាគីចំពោះការបន្តដំណើរការនីតិវិធី ដោយអវត្តមានលោក អៀង សារី

នៅថ្ងៃអង្គារ តាមរយៈចៅក្រម **ស៊ីលវៀល ខាត់វ៉ាយថ៍** អង្គជំនុំជម្រះបានអញ្ជើញភាគី ដើម្បីឲ្យពួកគេជួយផ្តល់មតិយោបល់ថាតើមានរបៀបសមរម្យណាខ្លះដែលអង្គជំនុំជម្រះ គួរតែបន្តការធ្វើបទបង្ហាញនៃឯកសារ ក៏ដូចជាការស្តាប់សក្ខីកម្មរបស់សាក្សីនានា ដោយពិចារណាទៅលើស្ថានភាពរបស់លោក **អៀង សារី** បើគាត់នៅតែបន្តការសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត (ពេទ្យរុស្ស៊ី)។[43]

មេធាវីអន្តរជាតិការពារក្តីលោក **អៀង សារី** គឺលោក **ម៉ៃឃើល កាណាវ៉ាស** បានថ្លែងថា ដូចក្តីខ្លួនបានយល់ព្រមលះបង់សិទ្ធិមិនស្តាប់សក្ខីកម្មរបស់សាក្សីប្រមាណជា ២០ នាក់ ។ វាអាចមានករណីនឹកស្មានមិនដល់ ដែលការផ្តល់សក្ខីកម្មណាមួយអាចនឹងទាញឲ្យលោក **អៀង សារី** ទទួលរងនូវលទ្ធផលអវិជ្ជមាន ហើយម្យ៉ាងវិញទៀត បើយោងតាមលោក **កាណាវ៉ាស** ថា ភាគីព្រះរាជអាជ្ញា

ធ្លាប់បានចង្អុលបង្ហាញថា បើមានរឿងហេតុបែបនេះកើតឡើងពិតមែន ភាគីការពារក្តីអាចស្នើឲ្យកោះហៅសាក្សីណាម្នាក់មកស្រាយបំភ្លឺឡើងវិញបាន ។ បន្ថែមពីនេះ ជនជាប់ចោទក៏មានសិទ្ធិឲ្យមេធាវីប្រឹក្សាក្តីរបស់គាត់ធ្វើជាតំណាងឲ្យគាត់ ក្នុងពេលមានសវនាការទាក់ទងនឹងការដាក់បង្ហាញឯកសារ ។ មេធាវីការពារក្តីលោក **អៀង សារី** បានគូសបញ្ជាក់ថា ពួកគេបានព្យាយាមគ្រប់លទ្ធភាពដើម្បីមិនឲ្យមានការពន្យារពេលដំណើរការនីតិវិធីកាន់តែវែងឆ្ងាយថែមទៀត ហើយថាចន្លោះពេលប៉ុន្មានខែទៅមុខនេះ តុលាការក៏មានកិច្ចការជាច្រើនដែលអាចធ្វើទៅបាន ដោយមិនចាំបាច់ធ្វើការពន្យារពេលរងចាំវត្តមានរបស់លោក **អៀង សារី** ។ មេធាវីអន្តរជាតិការពារក្តីលោក **នួន ជា** គឺលោក **ហ្សាស្ពឺ ប៉ៅ** ព្រមទាំងមេធាវីអន្តរជាតិរបស់លោក **ខៀវ សំផន** លោកស្រី **អេនតា ហ្គីហេ្ស** បានផ្តល់ការគាំទ្រដល់ការលើកឡើងពីក្រុមការពារក្តីលោក **អៀង សារី** ។ ចំណែកឯមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោកស្រី **អេលីហ្សាបេត ស៊ីម៉ុនណូហ្វត** បានយល់ស្របថា កិច្ចដំណើរការនីតិវិធីគួរតែបន្តទៅមុខ ហើយអង្គជំនុំជម្រះ គួរស្តាប់សក្ខីកម្មសាក្សីស្តីពីការជម្លៀស ដោយបង្ខំ ។

ដោយបញ្ជាក់ពីអ្វីដែលលោក **កាណាវ៉ាស** បាននិយាយពីខាងដើម ព្រះរាជអាជ្ញាអន្តរជាតិលោក **វីលៀម ស្មីត** បានថ្លែងថា តុលាការមានបញ្ហាគ្រប់គ្រាន់ដែលត្រូវដោះស្រាយរហូតដល់បុណ្យណូអែល ។ ក្រៅពីបានលះបង់សិទ្ធិមិនស្តាប់សក្ខីកម្មសាក្សីមួយចំនួន លោក **អៀង សារី** ក៏បានអនុញ្ញាតឲ្យក្រុមការពារក្តីរបស់គាត់ អាចធ្វើជាតំណាងការពារក្តីឲ្យខ្លួនក្នុងសវនាការស្តីពីការដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនង ព្រមទាំងឲ្យមេធាវីធ្វើជាតំណាងឲ្យគាត់ នៅក្នុងអំឡុងពេលនៃកិច្ចដេញដោលលើការប្រើប្រាស់ភស្តុតាងជំនួយ ។ ព្រះរាជអាជ្ញាក៏បានពន្យល់ថា សក្ខីកម្មសាក្សីបន្ទាប់ មិនត្រូវពាក់ព័ន្ធនឹងសកម្មភាព និងការប្រព្រឹត្តផ្សេងៗរបស់ **អៀង សារី** ឡើយ ។ ប៉ុន្តែប្រសិនបើមានការលើកឡើងនូវភស្តុតាងណាមួយ ដែលអាចទាក់ទងនឹងជនជាប់ចោទ **អៀង សារី** មែននោះ លោក **ស្មីត** បានថ្លែងថា ពួកគាត់អាចកោះហៅសាក្សីមកសួរដេញដោលជាថ្មីម្តងទៀតនៅពេលដែលជនជាប់ចោទ **អៀង សារី** បានធូរស្បើយពីជម្ងឺវិញ ឬយើងនឹងកាត់ចោលនូវព័ត៌មានជាប់ពាក់ព័ន្ធទាំងនោះចេញពីប្រតិចារឹក ។

## *ជំពូកទី៣ ៖* **ការគ្រប់គ្រងតុលាការ**

ផ្អែកលើការលះបង់សិទ្ធិមានវត្តមានក្នុងសវនាការរបស់លោក **អៀង សារី** ធ្វើឲ្យតុលាការមានឱកាសបន្តកិច្ចដំណើរការនីតិវិធីនៅក្នុងសប្តាហ៍នេះ ដោយអាចធ្វើទៅបានចាប់ពីថ្ងៃច័ន្ទដល់ថ្ងៃព្រហស្បតិ៍ ។ ជាថ្មីម្តងទៀត អង្គជំនុំជម្រះបានអញ្ជើញឲ្យភាគីដាក់សំណើជូនអង្គជំនុំជម្រះអំពីរបៀបដែលកិច្ចដំណើរការនីតិវិធីគួរតែត្រូវបានបន្តតាមវិធីផ្សេង ដោយសារលក្ខខណ្ឌសុខភាពរបស់លោក **អៀង សារី**។ ភាគីទាំងអស់ បានធ្វើការគូសបញ្ជាក់ថា តុលាការមានភារកិច្ចគ្រប់គ្រាន់ដើម្បីដោះស្រាយចាប់ពីពេលនេះទៅ រហូតដល់បំណាច់ឆ្នាំ ។ អង្គជំនុំជម្រះបានបន្តព្យាយាមគ្រប់គ្រងពេលវេលា ដោយរម្លឹកភាគីទាំងអស់ឲ្យលើកឡើងនូវការសម្តែងមតិយោបល់រៀងៗខ្លួនក្តី ទាំងការជំទាស់តវ៉ានានាក្តី គឺត្រូវធ្វើឲ្យបានច្បាស់ៗ និងចំៗ ហើយបានណែនាំសាក្សីថា មិនត្រូវធ្វើការ

សម្រេចចិត្តដោយឯកឯង ឬជាឯកតោភាគីមិនឆ្លើយនឹងសំណួរដែលខ្លួនចាត់ទុកថា មិនជាប់ពាក់ព័ន្ធច្រំដែល ឬប៉ាន់ស្មាននោះទេ ។ ដោយសារតែមានការខ្វះខ្វែង រក្សាឲ្យបាននូវកិច្ចដំណើរការនីតិវិធីមួយគ្មានភាពរអាក់រអួល ភាពអត់ធ្មត់របស់អង្គជំនុំជម្រះត្រូវបានបាត់បង់ នៅពេលមានការដាក់សំណើផ្សេងៗពីក្រុមការពារក្ដីលោក **នួន ជា** ។

## ក. វត្តមាន

លោក **អៀង សារី** នៅតែបន្តសម្រាកព្យាបាលក្នុងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដូច្នេះ គាត់បានអវត្តមានពេញមួយសប្ដាហ៍ ។ តាំងពីថ្ងៃច័ន្ទ ដល់ថ្ងៃព្រហស្បតិ៍ លោក **នួន ជា** បានចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងបន្ទប់សវនាការនាពេលព្រឹក ហើយបានសម្រាកនៅបន្ទប់ឃុំខ្លួនជាន់ក្រោមដើម្បីតាមដានសវនាការពីចម្ងាយនាពេលរសៀល ។ មានតែលោក **ខៀវ សំផន** ទេ ដែលបានស្ថិតនៅក្នុងបន្ទប់សវនាការគ្រប់វគ្គក្នុងសប្ដាហ៍នេះ ។

**វត្តមានដើមបណ្ដឹងរដ្ឋប្បវេណី៖** មានដើមបណ្ដឹងរដ្ឋប្បវេណីប្រមាណពី ១០ ទៅ ២០នាក់ បានចូលរួមកិច្ចដំណើរការសវនាការជារៀងរាល់ថ្ងៃ ក្នុងបន្ទប់សវនាការ និងក្នុងសាលសាធារណៈ ។

**វត្តមានភាគី៖** ភាគីទាំងអស់ មានវត្តមានត្រឹមត្រូវក្នុងអំឡុងសវនាការសប្ដាហ៍នេះ ។

**វត្តមានសាធារណជន ៖**

| កាលបរិច្ឆេទ | ពេលព្រឹក | ពេលរសៀល |
|---|---|---|
| ថ្ងៃច័ន្ទ<br>០១/១០/១២ | ▪ អ្នកភូមិប្រហែល ៣០០ នាក់ មកពីស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង<br>▪ អ្នកសង្កេតការណ៍បរទេស មានច្រើនជាង ២០ នាក់ | ▪ អ្នកភូមិប្រហែល ១៥០ នាក់ មកពីស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ |
| ថ្ងៃអង្គារ<br>០២/១០/១២ | ▪ អ្នកភូមិប្រហែល ៤០០ នាក់មកពីស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង<br>▪ អ្នកសង្កេតការណ៍បរទេសមាន ៤ នាក់ | ▪ អ្នកភូមិប្រហែល ២០០ នាក់មកពីស្រុកត្រាំកក់ ខេត្តតាកែវ<br>▪ អ្នកសង្កេតការណ៍បរទេសមាន ២ នាក់ |
| ថ្ងៃពុធ<br>០៣/១០/១២ | ▪ អ្នកភូមិប្រហែល ២៥០ នាក់មកពីស្រុកកំពង់ត្រាច ខេត្តកំពត<br>▪ អ្នកសង្កេតការណ៍បរទេស មាន ៣ នាក់ | ▪ អ្នកភូមិប្រហែល ១៥០ នាក់មកពីស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង |
| ថ្ងៃព្រហស្បតិ៍<br>០៤/១០/១២ | ▪ យុវជនប្រហែល ២០០ នាក់មកពីសមាគមន៍យុវជនកម្ពុជា ស្រុកកៀនស្វាយ ខេត្តកណ្ដាល | ▪ អ្នកភូមិប្រហែល ១០០ នាក់មកពី ស្រុកសម្រោង ខេត្តតាកែវ<br>▪ អ្នកសង្កេតការណ៍បរទេសមាន ១ នាក់ |

## ខ. ការគ្រប់គ្រងពេលវេលា

អង្គជំនុំជម្រះ និងភាគីបានបន្តចូលរួមគ្រប់គ្រងពេលវេលាបានល្អប្រសើរ ជាឧទាហរណ៍ជាក់ស្តែង លោក **អៀង សារី** និងក្រុមការពារក្តីរបស់គាត់ បានព្យាយាមមិនពន្យារពេលនៃកិច្ចដំណើរការនីតិវិធីទេ គឺថាអំឡុងពេលដែលជនជាប់ចោទ **អៀង សារី** បានធូរស្បើយពីស្ថានភាពជម្ងឺ អង្គជំនុំជម្រះក៏បានរិះរកវិធីចម្រាញ់មតិយោបល់ពីភាគី លើរបៀបដែលតុលាការត្រូវបោះជំហ៊ាននៃការកាត់សេចក្តីដូចម្តេចតទៅមុខទៀត ដើម្បីប្រើពេលវេលាឲ្យកាន់តែមានប្រសិទ្ធភាព ។

នៅថ្ងៃព្រហស្បតិ៍ ក្រោយពីការលើកឡើងនូវការជំទាស់ពីសំណាក់មេធាវី **អ៊ីនូហ្ស៊ី** ចំពោះវិធីសាស្ត្រតាំងសំណួររបស់ព្រះរាជអាជ្ញា **អាប់ឌុលឡាក់** ។ លោកមេធាវីជឿជាក់ថា វាជាសំណួរបង្កប់ដោយចេតនាទាញយកព័ត៌មានចេញមកពីចម្លើយសារភាព ដែលបានមកពីការធ្វើទារុណកម្មរបស់ **ជូ ជេត** ហៅ “ស៊ី” សហព្រះរាជអាជ្ញាបានតបនឹងការជំទាស់ថា ពួកគេកំពុងបាត់បង់ “ពេលវេលាដ៏មានតម្លៃ” សម្រាប់ការតាំងសំណួរ (តាមរយៈការជំទាស់) ។ ឮដូចនេះ មេធាវី **អ៊ីនូហ្ស៊ី** បានយល់ព្រមផ្តល់ពេលវេលាផ្ទាល់របស់ក្រុមខ្លួន បន្ថែមទៅឲ្យភាគីសហព្រះរាជអាជ្ញាសម្រាប់ការតាំងសំណួរ (កាត់ពេលវេលារបស់ក្រុមការពារក្តី **នួន ជា** ឲ្យទៅសហព្រះរាជអាជ្ញា) ។ ប៉ុន្តែអង្គជំនុំជម្រះ បានកាត់សម្តីភ្លាម ហើយនិយាយថា “មិនមែនលោកអ្នកផ្តល់ពេលវេលាទេ ។ ពេលវេលាយើងជាអ្នកសម្រេចថា ឲ្យ ឬមិនឲ្យ គឺខាងអង្គជំនុំជម្រះទេ អ្នកសម្រេច”។ ក្រោយមក អង្គជំនុំជម្រះ តាមរយៈការស្នើរបស់ភាគីសហព្រះរាជអាជ្ញា និងក្រោយពីបានប្រឹក្សាយោបល់ជាមួយនឹងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានអនុញ្ញាតឲ្យភាគីសហព្រះរាជអាជ្ញា ១ ម៉ោង បន្ថែមទៀត ដើម្បីសួរដេញដោលលើសាក្សី ។ មេធាវី **អ៊ីនូហ្ស៊ី** ទោះបីជាបានកត់សម្គាល់ថា ខាងចុងចោទមិនត្រូវបានប្រឹក្សា បានថ្លែងថា ពួកគេមិនមានការជំទាស់លើការបន្ថែមម៉ោងទេ ។

## គ. ឥរិយាបថក្នុងបន្ទប់សវនាការ

សប្តាហ៍នេះ ការឆ្លើយឆ្លងសម្តីគ្នារវាងអង្គជំនុំជម្រះតុលាការដំបូងជាមួយនឹងមេធាវីការពារក្តីលោក **នួន ជា** មានសភាពយ៉ាប់យឺនកាន់តែខ្លាំងឡើង ។ នៅថ្ងៃអង្គារ មេធាវី **ប៉ៅ** បានទទូចសួរសាក្សី **ខៀវ អេន** អំពីទំនាក់ទំនងរបស់គាត់ជាមួយនឹងលោក **គីម វុន** (អតីតកម្មាភិបាលមួយរូប និងក៏ជាសាក្សី) ក្រោយកម្ពុជាប្រជាធិបតេយ្យ ទោះបីជាលោកប្រធានតុលាការ បានណែនាំមេធាវីឲ្យបន្តសំណួរថ្មី ព្រោះសំណួរនេះត្រូវបានសួររួចហើយ[44] និងថាជាសំណួរមិនមានភាពពាក់ព័ន្ធ ។ មេធាវី **ប៉ៅ** បានថ្លែងថា៖ “ខ្ញុំចង់បានសេចក្តីសម្រេចពីអង្គជំនុំជម្រះសាលាដំបូងទាំងមូលលើបញ្ហានេះ...ខ្ញុំសូមអញ្ជើញចៅក្រមអន្តរជាតិឲ្យផ្តល់ការសម្រេចលើបញ្ហានេះ ព្រោះវាហាក់បីដូចជាមានការយល់ច្រឡំ”។ លោកមេធាវីបានបន្តសួរអង្គជំនុំជម្រះថា “ប្រសិនបើខ្ញុំមិនអាចចោទសួរសាក្សីនេះបានទេនូវទំនាក់ទំនងដែលគាត់អាចមានជាមួយលោក **គីម វុន** ទាំងពេលបច្ចុប្បន្ន និងអតីតកាល តើវាមានន័យអ្វីទៀតក្នុងការសួរចម្លើយ?” ចៅក្រម **ខាតវ៉ាយថ៍** បានលើកឡើងអំពីសេចក្តី

សម្រេចរបស់លោកប្រធានតុលាការម្តងទៀត ថាសំណួរដែលមេធាវីសួរ គឺមិនមានភាពពាក់ព័ន្ធ ។ លោកស្រីបានបន្តថ្លែងថាអង្គជំនុំជម្រះមានការសោកស្តាយចំពោះការស្នើសុំឲ្យចៅក្រមនេះ ចៅក្រមនោះដោយចំពោះ (ជាតិ ឬអន្តរជាតិ) ក្នុងការផ្តល់សេចក្តីសម្រេចអ្វីមួយលើសំណើរបស់ខ្លួន ។ ដើម្បីឲ្យកាន់តែច្បាស់លាស់ថែមទៀត ជាមួយមេធាវីការពារក្តីលោក **នួន ជា** យើងសូមជម្រាបថា អង្គជំនុំជម្រះសាលាដំបូងទាំងមូលបានយល់ស្របនឹងសេចក្តីសម្រេចរបស់លោកប្រធានចៅក្រម!

នៅព្រឹកថ្ងៃពុធ ក្រោយពីលោកប្រធានតុលាការ **និល ណុន** បានគូសបញ្ជាក់ថា អង្គជំនុំជម្រះ បានកត់សម្គាល់ចំពោះការដាក់សំណើរបស់មេធាវី **អ៊ីនូហ្សុី** ដែលសុំឲ្យគូសចោលផ្នែកខ្លះនៃចម្លើយរបស់សាក្សី **មាស វឿន** ទៅកាន់សហចៅក្រមស៊ើបអង្កេតរួចមក លោកប្រធានក៏បានប្រកាសសម្រាកកិច្ចដំណើរការនីតិវិធីភ្លាមៗដែរ (មើលជំពូកទី៤ គ) ។ ទោះបីជាចៅក្រមបានចាប់ផ្តើមដើរចេញពីបន្ទប់សវនាការទៅហើយ ក៏មេធាវី **អ៊ីនូហ្សុី** បាននិយាយថា គាត់បានដាក់សំណើផ្ទាល់មាត់ ដូច្នេះ គាត់គួរតែបានឮនូវមតិយោបល់តបរបស់សហព្រះរាជអាជ្ញា ហើយដែលអង្គជំនុំជម្រះគួរតែចេញសេចក្តីសម្រេចលើការដាក់សំណើនេះ ។ មេធាវីបានបន្តថា “ឥឡូវនេះ ខ្ញុំឃើញអ្នកទាំងអស់គ្នាបានក្រោកឡើង ហើយដើរចេញពីទីនេះ ប៉ុន្តែលោក លោកស្រីគឺជាចៅក្រម ជាអ្នកដែលមាននាទីត្រូវតែអាចដោះស្រាយបញ្ហានេះ...ការដើរចេញមិនអាចដោះស្រាយបញ្ហាបានទេ” ។ នៅថ្ងៃដដែល ខណៈសវនាការចាប់ផ្តើមនៅពេលរសៀលភ្លាម ចៅក្រម **ខាតវ៉ាយច៍** បាននិយាយថា ការដាក់សំណើផ្ទាល់មាត់របស់មេធាវី ត្រូវបានពិចារណាដោយអង្គជំនុំជម្រះ ហើយ “មិនចាំបាច់មេធាវីមកណែនាំពីកំហុសឆ្គងរបស់អង្គជំនុំជម្រះ ដែលមិនបានមើលឃើញពីបញ្ហា”។ ក្រោយពីចៅក្រម **ខាតវ៉ាយច៍** បានលើកឡើងនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ មេធាវី **អ៊ីនូហ្សុី** បានថ្លែងថា គាត់យល់ពីការកត់សម្គាល់ចុងក្រោយរបស់លោកប្រធាន មុនពេលសម្រាកអាហារថ្ងៃត្រង់ក្នុងការច្រានចោលសំណើរបស់គាត់ ព្រោះលោកប្រធាន បាន “សម្គាល់ចរិកលក្ខណៈ” របស់វាថាជា “កំហុសនីតិវិធី” ដើម្បីជាមូលដ្ឋានធ្វើការ“មោឃភាពសំណើ”របស់យើងខ្ញុំ ហើយដោយសារតែហេតុផលនេះហើយ ដែលយើងខ្ញុំនៅតែទទូចចង់និយាយឲ្យដឹងហេតុផល ។ បន្ទាប់មក មេធាវីបានចង្អុលបង្ហាញថា គាត់មានការដឹងគុណចំពោះការចេញសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះ ។

ទំនាក់ទំនងរឹតតែតានតឹងឡើងៗ នៅរសៀលថ្ងៃព្រហស្បតិ៍ នៅពេលមេធាវី **អ៊ីនូហ្សុី** បានយោងលើអត្ថបទមួយរបស់*កាសែតខាំបូឌាដេលី* លើសំណុំរឿងលោក **ម៉ម សូណង់ដូ** ដែលមានចំណងជើងថា “សាលក្រមរបស់លោក **ម៉ម សូណង់ដូ** គឺជាការធ្វើតេស្តទៅលើភាពយុត្តិធម៌នៅប្រទេសកម្ពុជា ”។ យោងតាមលោក **អ៊ីនូហ្សុី** ថាអត្ថបទនេះបានឆ្លុះបញ្ចាំងនូវ “ការបរាជ័យ” នៃ **អ.វ.ត.ក** ក្នុងការមិនមានឥទ្ធិពលអ្វីលើប្រព័ន្ធយុត្តិធម៌ជាតិ ។ មេធាវីបានដកស្រង់ចេញពីអត្ថបទដែលមានខ្លឹមសារដូចតទៅ៖ “វាឆ្ងាយពីការកំណត់នូវគំរូល្អមួយ គឺសាលាក្តីខ្មែរក្រហម អាចត្រឹមតែបានធ្វើផ្ទុយពីការកំណត់នូវគំរូនេះ ។ នេះជាសម្តីរបស់លោក **រ៉ូពឹត អេបបុត** ជាអ្នកស្រាវជ្រាវការលើកលែងទោសអន្តរជាតិអាស៊ីសម្រាប់កម្ពុជា”។ លោក **អ៊ីនូហ្សុី** បានស្នើថា “អ្នករាល់គ្នាអាចរកអានបាន” ហើយធ្វើការឆ្លើយតបជូនតុលាការនៅថ្ងៃច័ន្ទក្រោយ ហើយដែលបន្ទាប់ពីនេះ សេចក្តី

សម្រេចមួយពីអង្គជំនុំជម្រះគួរតែនឹងត្រូវធ្វើឡើង “ថាតើវាជាប្រធានបទមួយសមរម្យ ឬអត់ សម្រាប់ការពិភាក្សាក្នុងតុលាការ”។ ក្រោយពីមេធាវី **អ៊ីនូហ្ស៊ី** បានធ្វើសំណើផ្ទាល់មាត់នេះចប់ លោកប្រធានតុលាការមិនបានឆ្លើយតបអ្វីឡើយ តែភ្លាមៗបង្គាប់ឲ្យព្រះរាជអាជ្ញាបន្តការតាំងសំណួរលើសាក្សី **មាស វឿន**។ ក្រោយមកនាពេលរសៀល មេធាវី **អ៊ីនូហ្ស៊ី** បានទទូចម្តងទៀតថា អង្គជំនុំជម្រះ គួរតែពិចារណាលើបញ្ហាកើ្តដំណែលតុលាការដែលបានបន្សល់ទុក ហើយបន្តនិយាយថា៖

> *ហើយគួរឲ្យយើងមានការខ្មាសអៀនដែរ ដែលត្រូវមកតតទល់ជាមួយអ្នកទាំងអស់គ្នា ហើយក៏រឹតតែគួរឲ្យខ្មាសទៅទៀតចំពោះអង្គចៅក្រម ដែលកំពុងអង្គុយក្នុងបន្ទប់នេះទាំង៧រូប រួមគ្នាធ្វើការបង្វែងអង្គហេតុ ។ ទោះជាយ៉ាងនេះក្តី ហេតុការណ៍ដែលកើតមានឡើង លោក លោកស្រីចៅក្រមមិនអាចបង្វែង ឬគេចវេសបាន ដោយត្រឹមតែអង្គុយ នៅមុខជញ្ជាំងធ្វើពីកញ្ចក់មួយផ្ទាំងនេះ ។ ការកាត់មីក្រូហ្វូនរបស់ខ្ញុំដោយស្រួលៗ ដូចដែលធ្លាប់ធ្វើកន្លងមក អាចមានន័យថា លោក លោកស្រីមិនចង់ស្តាប់សំឡេងរបស់ខ្ញុំ ដូច្នេះ ហើយធ្វើឲ្យសាធារណជនអាចយល់ថាខ្ញុំជាអ្នករំខានដល់ដំណើរការនីតិវិធីហើយ ធ្វើដូចនេះ គឺធ្វើឲ្យគាត់មិនសប្បាយចិត្តនឹងតុលាការមួយនេះ ។*

លោកប្រធានចៅក្រមបានបង្អាក់មេធាវី ហើយបង្គាប់ឲ្យគាត់ដាក់សំណើជាលាយលក្ខណ៍អក្សរ ដោយមានហេតុសមរម្យ បើមានការកើតទុក្ខមិនសុខចិត្តរឿងអ្វីមួយ ។ មុនពេលចេញបង្គាប់ឲ្យមេធាវី **អ៊ីនូហ្ស៊ី** អង្គុយចុះ ហើយមិនឲ្យបន្តជជីកដេញដោលលើបញ្ហានេះទៀត លោកប្រធានចៅក្រម បាននិយាយថា៖

> *អង្គជំនុំជម្រះមិនមែនធ្វើដើម្បីលោកសប្បាយចិត្តទេ គឺធ្វើដើម្បីត្រឹមត្រូវ ដើម្បីភាពឿនលឿន យុត្តិធម៌ ដើម្បីឲ្យមានប្រសិទ្ធភាព។ មិនមែនចេះតែឲ្យលោកលើកអីក៏បានតាមតែចិត្តនោះទេ។*

## ឃ. តារាងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្ដើម | ការសម្រាក ពេលព្រឹក | អាហារថ្ងៃត្រង់ | ការសម្រាក ពេលរសៀល | បិទសវនាការ | ចំនួនម៉ោងសរុប |
|---|---|---|---|---|---|---|
| ថ្ងៃច័ន្ទ ០១/១០/១២ | ៩:០៤ | ១០:៣៣-១០:៥៣ | ១២:០៤-១៣:៣១ | ១៤:៤២-១៥:០៩ | ១៦:០៦ | ៤ ម៉ោង និង ៤៨ នាទី |
| ថ្ងៃអង្គារ ០២/១០/១២ | ៩:០១ | ១០:៣២-១០:៥៣ | ១២:០៥- ១៣:៣០ | ១៤:២៣- ១៥:០០ | ១៦:០៧ | ៤ ម៉ោង និង ៤៣ នាទី |
| ថ្ងៃពុធ ០៣/១០/១២ | ៩:០២ | ១០:២៧-១០:៤៩ | ១២:២៨-១៣:៤៦ | ១៤:៤៣-១៥:០២ | ១៦:០១ | ៥ ម៉ោង |
| ថ្ងៃព្រហស្បតិ៍ ០៤/១០/១២ | ៩:០០ | ១០:៣៣-១០:៥២ | ១២:០៩-១៣:៣៣ | ១៤:៤១-១៥:០២ | ១៦:០៣ | ៤ ម៉ោង និង ៥៩ នាទី |
| ចំនួនម៉ោងជាមធ្យមក្នុងសវនាការមួយថ្ងៃ ៖ | ៤ ម៉ោង និង ៥២ នាទី | | | | | |
| ចំនួនម៉ោងសរុបក្នុងសប្ដាហ៍នេះ ៖ | ១៩ ម៉ោង និង ៣០ នាទី | | | | | |
| ចំនួនសរុបនៃម៉ោងថ្ងៃនិងសប្ដាហ៍ ៖ | ៤៩៩ ម៉ោង និង ៤២ នាទី | | | | | |
| **១១៤ថ្ងៃ និង ៣៤សប្ដាហ៍** | | | | | | |

**Unless specified otherwise,**

- the documents cited in this report pertain to *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* before the ECCC;
- the quotes are based on the personal notes of the trial monitors during the proceedings;
- the figures in the *Public Attendance* section of the report are only approximations; and
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of Kaing Guek Eav alias "Duch"*(Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |
| GRUNK | Royal Government of National Union of Kampuchea |
| ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 (2011) |
| KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the ECCC |
| RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

[*] AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center, University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

This issue of **KRT Trial Monitor** was authored by Faith Suzzette Delos Reyes, Daniel Mattes, Hava Mirell, Noyel Ry, and Penelope Van Tuyl, as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT Trial Monitor reports on Case 002 are available at <www.krtmonitor.org>, and at the websites of the East-West Center and the War Crimes Studies Center.

[1] In accordance with Internal Rule 81 (1) and Articles 14 (1) and 14 (3) (d) of the International Covenant for Civil and Political Rights, Accused Ieng Sary issued a Limited Waiver, agreeing to waive his direct presence in

the courtroom for 1 Civil Party and 7 witnesses. He explicitly stated that he is not waiving his right to be present for other witnesses. See Ieng Sary. "Limited Waiver" (18 September 2012). E229. Due to his extended stay in the hospital, he subsequently issued another Limited Waiver for 11 additional witnesses and 7 Civil Parties. See Ieng Sary. "Limited Waiver" (1 October 2012). E237.

[2] Khiev En was examined in the following order: national Prosecutor Seng Bunkheang; international Prosecutor Dale Lysak; national Civil Party Lawyer Lor Chunthy; international Civil Party Lawyer Beini Ye; Judge Jean-Marc Lavergne; and Nuon Chea's counsels, Mr. Son Arun and Mr. Jasper Pauw.

[3] Office K-33 at the Ministry of Propaganda was responsible for "capturing data from various foreign language sources, translating that information and forwarding it to the Party Centre." Office of the Co-Prosecutors. "Co-Prosecutors' Rule 66 Final Submission (Public Redacted Version)" (16 Aug. 2010). D390. Para. 151.

[4] There was some confusion regarding Khiev En's birth year. While his citizen identification card states that his birth year is 1958, he insists that he was actually born in the Year of the Snake, and if he were to calculate it based on the Khmer year, his actual birth year would be either 1952 or 1953.

[5] When asked by Nuon Chea's international defense lawyer, Jasper Pauw, about the details of the bombardment, the Witness claimed that he saw planes "made in America" flying over the area. He could not recall whether people died in the bombardment, but he mentioned that Revolutionary Forces had entered the village the night before to evacuate residents.

[6] The Witness added that the defrocking occurred before he personally joined the Revolution.

[7] Hu Nim alias "Brother Phoas" was the Minister of Propaganda from April 1975 until his arrest and deportation to S-21 in April 1977. OCIJ. "Closing Order" (15 September 2010). D427 [hereinafter **CLOSING ORDER**] para. 883.

[8] Civil Party Lawyer Beini Ye manifested that Sam is listed as Prisoner 5619 in the Revised S-21 Prisoner List and that he arrived at S-21 from the Ministry of Propaganda on 10 April 1977 and was executed on 20 July 1977.

[9] The Witness noted that, in practice, the word "arrest" was not used. Instead, authorities used phrases such as "be removed for re-education" when they came to remove individuals. Regardless, the Witness explained, "when people were removed from one place to another during that regime, it referred to that person being arrested."

[10] Yun Yat alias "At" (Son Sen's wife) was initially just the Minister of the Ministry of Culture, Training and Education. After Hu Nim was arrested and sent to S-21 in April 1977, the Ministry of Information and Propaganda was reorganized and merged with the Ministry of Culture, Training and Education. At that time, Yun Yat became the minister for both. CLOSING ORDER, para. 883.

[11] The Witness stated that he Ministry of Education was located near Borei Keila, while the Ministry of Propaganda was located adjacent to the Lycée Descartes.

[12] According to Khiev En, Nuon Chea had a workspace in the "main building" adjacent to the smaller building where the Witness carried out his work. The Witness stated that Nuon Chea's work station was "open" and "there was no proper closed office'

[13] The Witness recalled that under Nuon Chea's leadership, workers enjoyed increased food rations, including cooked rice and an occasional dessert. He also stated that the Accused forbade employees from smoking in the workplace and encouraged them to exercise regularly to stay healthy.

[14] Kim Vun alias "Chhaom" testified before the Trial Chamber on 21 and 22 August 2012. He worked in various offices in the Ministry of Propaganda and Education between 1975 and 1979. See CASE 002 KRT TRIAL MONITOR, Issue No. 33, Hearing on Evidence Week 28 (20-23 August 2012).

[15] Meas Voeun was questioned by national Prosecutor Veng Huot, followed by international Prosecutor Tarik Abdulhak and national Civil Party Lawyer Pich Ang.

[16] Vorn Vet was one of the 20 people who participated in the Cambodian communists' first Congress in 1960. He was in charge of the Special Zone and later became a member of the CPK Central Committee's "Specialist Military Committee". He was also a member of the Party Standing Committee and was later appointed as Deputy Prime Minister for Economics. CLOSING ORDER, paras. 20, 31, 39, 43 and 63.

[17] The Closing Order refers to "Soeung", who was attached to the CPK Central Committee among other senior leaders. CLOSING ORDER, para. 38. The Closing Order also refers to "Soueng", who commanded military forces that supervised Koh Kyang Detention Centre in Sector 37 in the West Zone. CLOSING ORDER, para. 519. Witness Meas Voeun repeatedly explained that Ta Soeung was his direct superior, Commander of Division 1 of the Southwest Zone, and authored some telegrams from the "Western Division". For purposes of consistency, all references to the Commander of Division 1 are spelled as "Soeung"

[18] Hou Yun was involved with Hu Nim and Khieu Samphan in appealing to Phnom Penh residents and monks to "rise up and smash the enemy" prior to the city's liberation. CLOSING ORDER, para. 1130.

[19] Hu Nim worked with Son Sen and Khieu Samphan in preparation for the invasion and occupation of Phnom Penh in April 1975. He was later appointed as Minister for Propaganda. CLOSING ORDER, paras. 63 and 1155

[20] According to the Witness, he learned from Ta Soeung that the division commanders received orders in a meeting with the "General Staff", which included Son Sen and Nuon Chea, for the commanders to disseminate to the lower ranks.

[21] Witness clarified that, "these 2,700 soldiers were stationed close to my regiment, but then they suffered from malaria then, most of them had to return back and that left only a few hundred there."

[22] Chou Chet was one of 27 members who, in early 1971, attended a CPK Central Committee meeting; it was the first meeting of the Central Committee since October 1966. The Secretary of the West Zone "was Chou Chet alias Si until his arrest in March 1978. The West zone committee would regularly report to Office 870 on the

situation of the internal and external enemies." CLOSING ORDER, paras. 28 and 538.

[23] Meas Voeun was asked about three telegrams in particular: (i) Telegram 45, authored by "Office 09, Koh Kong," with "Western Division, Political Section" at the top left corner of the page, dated 6 October 1977, Document E3/137; (ii) Telegram, authored by "Western Division, Political Section," signed by "Soeung," annotated with name "Khiev," dated 12 August 1977, Document E3/1031. Witness confirmed that "Soeung" was likely Ta Soeung, and that the alias "Khiev" at the General Staff level referred to Son Sen; (iii) Telegram, authored in West Zone, signed by "Soeung," dated 31 March, 1978, Document E3/1001.

[24] Witness testified that, in fact, Ta Soeung kept his office in Prey Nup, but he worked in Kampong Som as well.

[25] When asked about the fate of Chou Chet, Secretary of the Western Zone, the Witness stated, "As far as I know, he did not stay in that position until the end! it was an affair between himself and the Center." According to the Witness, Center referred to Pol Pot and Ta Mok.

[26] The two documents cited by Prosecutor Abdulhak are: (i) Report "To respected and beloved Angkar," authored by Office M401, Document E3/1220; (ii) "To respected, beloved, and missed Angkar," Monthly Report to Angkar, authored by Office M401, dated 4 August 1978, Document E3/1094. Witness clarified that he had already departed from Koh Kong by the dates described in the latter report.

[27] The Witness learned from Ta Soeung that the latter was nominated as Chairman of the new North Zone. Although Meas Voeun could not say who previously held the position, he "knew it was Ta Mok" who had nominated Ta Soeung.

[28] IR 89 bis.states: The President shall order the Greffiers to read the counts against the Accused and may order the Greffier to read the factual analysis in the Indictment.

[29] See **CLOSING ORDER, paras. 113 to 149.**

[30] See ibid, paras. 156 to 159.

[31] See ibid, paras. 160 to 165.

[32] Movement of the Population from Phnom Penh.

[33] Movement of the Population from the Central (Old North), Southwest, West and East Zones.

[34] See **CLOSING ORDER, paras. 221 to 281.**

[35] See ibid, paras. 873 to 879 on Nuon Chea's alleged role in the security apparatus; 893 to 901 on his association with other CPK senior leaders and participation in population movement phases one and two; and 1580 to 1584 on the character of the Accused.

[36] See ibid, paras. 1016 to 1024 on Ieng Sary's association with other CPK senior leaders and participation in population movement phases one and two; and 1589 to 1597 on the character of the Accused.

[37] See ibid, paras. 1146 on Khieu Samphan's role in the military; 1151 to 1162 on his association with other CPK senior leaders and participation in population movement phases one and two; and 1601 to 1604 on the character of the Accused.

[38] Paragraph 282 states that 354 civil parties were found to have provided sufficient elements tending to establish prima facie personal harm as a direct consequence of crimes committed during the Movement of the Population from the Central (Old North), Southwest, West and East Zones (Phase 2).

[39] Pich Ang followed up by saying that paragraph 261 of the Closing Order was also not read; however, the President did not anymore address this matter.

[40] As explained by Andrew Ianuzzi, a motion in limine is "typically an oral application made prior to the testimony of a witness to exclude certain segments of the testimony."

[41] Ianuzzi referred to the evidence as "fruit of the poisonous tree -- that is, we have an illegal act, illegal violation, the use of illegal material -- so, that in itself is the poisonous tree! the fruit being the material that comes as a result of that." He also cited jazz musician Duke Ellington, saying: "'There are two kinds of music; good and bad.' I think there are two kinds of evidence, and this is clearly bad evidence and it should not be used before this Chamber."

[42] Article 15 of the UN Convention Against Torture and Other Cruel, Inhuman or Degrading Treatment or Punishment states: "Each State Party shall ensure that any statement which is established to have been made as a result of torture shall not be invoked as evidence in any proceedings, except against a person accused of torture as evidence that the statement was made."

[43] On 21 September 2012, the Chamber had invited Parties to give their positions relative to the hearing of the testimony of Expert Witness Philip Short, considering that Accused Ieng Sary was confined at the Khmer-Soviet Friendship Hospital. See CASE 002 KRT TRIAL MONITOR, Issue No. 36, Hearing on Evidence Week 31 (20-21 September 2012).

[44] The Witness said: "Chhaom (the alias of Kim Vun), actually, does not use telephone. He cannot even ride a motorbike. So, he does not hold any telephone at all. And I did not have - I do not have any intention to contact him for whatever reason. So, never bothered to ask him - or communicate with him at all."